**TKI0755**

## សម្ភាសន៍ជាមួយ ទុយ ថា ភេទស្រី អាយុ៥៤ឆ្នាំ ក្រៅប្រវត្តិរូប

## មុខងារៈ ប្រធានវរសេនាធំ តំបន់១៣ កងពល២១០

## សព្វថ្ងៃរស់នៅភូមិប្រាសាទ ឃុំកំពែង ស្រុកគិរីវង់ ខេត្តតាកែវ

## ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១០

## សម្ភាសន៍ដោយៈ ស សេងគា

## ០១:១៧:១៧

## ៣៦ទំព័រ

សេងគា : ជាដំបូងខ្ញុំណែនាំឈ្មោះខ្ញុំឲ្យអ៊ំបានស្គាល់ ខ្ញុំឈ្មោះ ស សេងគា ហើយបងខាងនេះគាត់ឈ្មោះបងវ៉ាស៊ី ផេង ពង្សវ៉ាស៊ី។ ខាងខ្ញុំទាំងពីរនាក់នឹង គឺមកពីខាងអង្គការមជ្ឈមណ្ឌលឯកសារកម្ពុជាស្វែងរកការពិតរឿងរ៉ាវដែលពិតប្រាកដ។ ហើយមកថ្ងៃនេះ គោលបំណងខាងខ្ញុំ គឺចង់សម្ភាសន៍អ៊ំជាសាច់រឿងរ៉ាវដែលអ៊ំបានចាំទាំងប៉ុន្មានកាលសម័យប៉ុលពតនឹង អ៊ំចាំបានអីខ្លះ ហើយអ៊ំបានឆ្លងកាត់រឿងរ៉ាវនឹងយ៉ាងម៉េចខ្លះ ហើយគេប្រើអ៊ំឲ្យធ្វើអីខ្លះ ដើម្បីយករឿងរ៉ាវនឹង ចងក្រងជាឯកសារ ដូចជាសរសេរជាទស្សនាវដ្ដីចេះសាច់រឿងអ៊ំនឹង ហើយនឹងអាចទុកចងក្រងជាឯកសារផ្សេងៗទៀត ដើម្បីឲ្យក្មេងៗបានសិក្សារៀនសូត្រ នឹងទុកស្រាវជ្រាវអីបន្តទៀត។ បើខ្ញុំអាត់ សួរអ៊ំ នៅពេលចប់យកបទសម្ភាសន៍អ៊ំទៅប្រើប្រាស់ អ៊ំយល់យ៉ាងម៉េចដែរ អ៊ំអនុញ្ញាតិឲ្យខាងខ្ញុំប្រើទេ?

ថា : រឿងការឲ្យប្រើមិនទាស់ រឿងបញ្ហាការងារនេះ វាអត់សូវចាំអស់មកពី៧៩ គិតការងាររកស៊ី អត់មានពាក់ព័ន្ធរឿងនឹងទៀត។

សេងគា : ដូចខ្ញុំនិយាយប្រាប់អ៊ំ អ៊ំចាំបានប៉ុណ្ណា អ៊ំឆ្លើយប៉ុននឹងមក បើអ៊ំថាមិនដឹងៗទៅ រឿងនឹងអីចឹងទេ។ ខ្ញុំនឹងសាក់សួរអ៊ំ ខ្ញុំចង់ស្គាល់ឈ្មោះអ៊ំដែរ? តើអ៊ំឈ្មោះអីដែរ?

ថា : ទុយ ថា។

សេងគា : អ៊ំអាយុប៉ុន្មានហើយ?

ថា : ៥៤។

សេងគា : រាល់ថ្ងៃប្រកបមុខរបរធ្វើអីដែរ?

ថា : ធ្វើស្រែ។

សេងគា : ស្រុកកំណើតនៅភូមិអី ឃុំអី ស្រុកអីដែរ?

ថា ៖ ស្រុកកំណើតដើម?

សេងគា ៖ បាទ!

ថា ៖ ស្រុកកំណើតដើមនៅអន្លង់វែង ។

សេងគា ៖ អន្លង់វែង ភូមិអី ឃុំអី?

ថា ៖ អន្លង់វែង ភូមិស្រែខ្ទាយ ឃុំអន្លង់វែងថ្មី ស្រុកទ្រាំង ។

សេងគា ៖ ភូមិស្រែខ្ទាយ ឃុំ?

ថា ៖ ឃុំអន្លង់វែង ដាក់ថ្មីក្រោយឃុំអន្លង់វែង ។

សេងគា ៖ ពីមុនខ្លាវ ដល់ពេលបច្ចុប្បន្នគេដូរឈ្មោះដាក់មកឃុំដូនកែវវិញ?

ថា ៖ មិនមែនទេ ហៅអន្លង់វែងម៉ង ដូចវែងវផ្សេង ។

សេងគា ៖ ស្រុក?

ថា ៖ ស្រុកទ្រាំង ។

សេងគា ៖ ស្រុកទ្រាំង?

ថា ៖ ខេត្តតាកែវ ។

វ៉ាស៊ី ៖ អន្លង់វែងនឹងនៅឃុំអី?

ថា ៖ ឃុំអន្លង់វែងម៉ង ភូមិស្រែខ្ទាយ ឃុំអន្លង់វែង ។

សេងគា ៖ ស្រុកទ្រាំងវិញ?

ថា ៖ ស្រុកទ្រាំង ។

សេងគា ៖ ថ្ងៃនេះថ្ងៃទី១៥ ខែ៧ ឆ្នាំ២០១០ ។ ចង់សាក់សួរអ៊ំពីរឿងរ៉ាវដែលអ៊ំបានឆ្លងកាត់កាលសម័យខ្មែរក្រហមនឹង? អ៊ំបានធ្វើអីខ្លះ ហើយកាលនឹង? ហើយធ្វើយ៉ាងម៉េចខ្លះ? អ៊ំអាចរៀបរាប់បានខ្លះទេ?

ថា ៖ ឈប់ស្តាប់មិនបានរៀបរាប់ ការប្រវត្តិ?

សេងគា ៖ បាទ! អ៊ំតាំងពីតូចមក តាំងពីរៀបរាប់ជីវប្រវត្តិរបស់អ៊ំ ពីតូចមកធ្វើអី អ៊ំរៀននៅសាលាណា ហើយរហូតមកបានធ្វើអីទៀត ។ អ៊ំអាចរៀបរាប់បានខ្លះទេ?

ថា ៖ បាទ! ដូចខ្ញុំថា ការងារមិនថាធ្វើហើយវាភ្លេចទេ ប៉ុនខានទឹកនាយូរវាភ្លេចខ្លះ ព្រោះអត់ដេកគិតរឿងប្រវត្តិនឹង បើយើងអត់មានគិតគូពីការងារ ដឹងថាការងាររកស៊ីធ្វើស្រែធ្វើចំការចិញ្ចឹមកូនប្រពន្ធ ។ ដូច្នេះរយៈពេលយូរឆ្នាំហើយ នៅភ្លេចភ្លាំងឈឺហឹងគ្រចៀកហ៊ឹងអី និយាយសឹងមិនចេញផង ។ ហើយរឿងប្រវត្តិការរស់នៅកន្លងមក ជីវប្រវត្តិតាំងពីចុះ

មក៧៩មក អានឹងធ្លាប់ធ្វើការងារធ្វើទ័ព បើសិនខ្ញុំបម្រើនយោបាយអាក្រក់ ក៏មិនអាចនៅដល់ឥឡូវដែរ ព្រោះវាស្មោះជាមួយប្រជាជនជាមួយអីចឹង ជាមួយអ្នកដឹកនាំអីចឹងទៅ ។ អីចឹងបានវាសុខសាន្តរកស៊ីធម្មតា ។ ហើយបើប្រវត្តិ និយាយពីប្រវត្តិផ្ទាល់ខ្លួនធ្វើទ័ព១ បើធ្វើពីមុន យើងកូនទាហាននាយអាយ ដល់ធ្វើយូរឡើងមេដែរ ។

សេងគា ៖ ម៉េចទៀតអ៊ំ?

ថា ៖ ហើយដល់រឿងការកាប់សម្លាប់ ការអី អានឹងការពិតខ្ញុំមិនដែលនៅជាមួយប្រជាជន មិនដែលនៅធ្វើសេនាជនធ្វើឈ្លប ខ្ញុំធ្វើទ័ពរហូតចូលទៅ ។ ដូច្នេះ ខាងក្រោយនេះខ្ញុំអត់ដឹងខ្ញុំដឹងរឿងប្រយុទ្ធជាមួយអ្នកអត់មានអាវុធដូចគ្នា ព្រោះខ្ញុំអត់ដែលនៅកិច្ចការជាមួយប្រជាជនផង ធើទ័ពរហូតចូលទៅ ។

សេងគា ៖ សុំបកមកសួរអ៊ំបន្តិច ។

ថា ៖ ទាល់តែសួរបានឆ្លើយ ។

សេងគា ៖ ឪពុកអ៊ំឈ្មោះអី?

ថា ៖ ឪពុកឈ្មោះ ម៉ូញ យ៉ង ។

សេងគា ៖ ម៉ូញ យ៉ង?

ថា ៖ ម៉ូញ យ៉ង ។

សេងគា ៖ ម្ដាយឈ្មោះអី?

ថា ៖ ខៀង ហ៊ិន ។

សេងគា ៖ ចុះប្រពន្ធអ៊ំឈ្មោះអី?

ថា ៖ សយ ជ្រិន ។

សេងគា ៖ អ៊ំមានកូនប៉ុន្មាននាក់?

ថា ៖ កូន៣ ។

សេងគា ៖ ប្រុសប៉ុន្មាន ស្រីប៉ុន្មាន?

ថា ៖ ស្រីទាំង៣ ។

សេងគា ៖ ហើយកូនបងអាយុប៉ុន្មាន?

ថា ៖ ធីអាយុប៉ុន្មានហើយ?

ប្រពន្ធ ៖ ៣១ ។

ថា ៖ ៣១ ។

សេងគា ៖ គាត់ឈ្មោះអី ធី?

ថា ៖ ទុយ ចាន់ធី ។

សេងគា ៖ កូនទី២ឈ្មោះអី?

ប្រពន្ធ ៖ ទុយ ចាន់ធឿន ។

សេងគា ៖ ហើយចុះកូនពៅ?

ប្រពន្ធ ៖ ទុយ ចាន់ ។

ថា ៖ ចាន់ធូ ។

សេងគា ៖ អ៊ំរៀបការនៅឆ្នាំណា?

ថា ៖ កាលជំនាន់នឹង៧៧ ខែប៉ុន្មានទេ ខែ១ ខែ២ ។

សេងគា ៖ រៀបការនៅសម័យប៉ុលពតដែរ?

ថា ៖ បាទ!

សេងគា ៖ ហើយកូនអ៊ំកើតទាន់សម័យប៉ុលពតទាំងអស់ទេ?

ថា ៖ អត់ទេ មកកើតនឹង ។

សេងគា ៖ សម័យប៉ុលអត់ទាន់កើតទេ ទាំងអស់នឹង?

ថា ៖ ចុះ៣១ គិតមើលកើត៩៧ ហើយ៨០គត់ ។

ប្រពន្ធ ៖ ចុះមកបានម៉ាឆ្នាំបានមានមីបង ។

សេងគា ៖ ចង់សួរថា ដំបូងស្រុកកំណើតអ៊ំនៅស្រុកទ្រាំង ដំបូងអ៊ំចូលរៀនអាយុប៉ុន្មានហើយ?

ថា ៖ អឺ! កាលនឹងនៅក្មេចអស់ហើយខ្ញុំ រៀនមិនដឹងអាយុប៉ុន្មានទេ រៀនបានអក្សរសាស្ត្រទេ រៀននៅអង្គកែវ វត្តអង្គកែវនឹងមិនសូវមានគ្រូទេ សាលាវត្តធម្មតាទេ ។ ឪយកផ្ញើនៅវត្តបារាយណ៍ អស់វត្តបារាយណ៍ទៅឆ្ងាយវត្តជ្រៃក្បាលគោនោះ ហើយនៅទីបញ្ចប់រៀនបានត្រឹមថ្នាក់ទី៩ ពេលវ៉ាក់កងមិនរដ្ឋប្រហារ វ៉ាកកងតូច ។ រៀនបានទី៩នឹង ក៏ចូលធ្វើទ័ពជាមួយគេ ជាមួយឯង ទើបអាយុ១៨ចូល ។

សេងគា ៖ រៀនៗបានត្រឹមថ្នាក់ទីប៉ុន្មាន?

ថា ៖ ទី៩ រៀនបានត្រឹមវ៉ាក់កងរដ្ឋប្រហារនឹង ទី៩បានប៉ុន្មានខែ ។

សេងគា ៖ ទី៩ ស្មើទីប៉ុន្មានឥឡូវ?

ថា ៖ ហ៊ា! មិនដឹងស្មើទីប៉ុន្មានទេ ។

សេងគា ៖ ទី៩ជំនាន់នឹង?

ថា ៖ ទេ! អ្នកចេះដឹង ចេះជាងដឹងហើយ ខ្ញុំមិនដឹងម៉េចដែរ ។

សេងគា ៖ ហើយរៀនអ៊ំអានអក្សរ អានបាន?

ថា ៖ បាន ចេះគួរសមដែលនឹង ព្រោះរៀននៅវត្តខំប្រឹងដែរ ឆ្ងាយពីផ្ទះ ។

សេងគា ៖ រៀននៅនឹង រៀននៅភូមិដដែល?

ថា ៖ កាលនៅរៀនឆ្ងាយទៅរៀននៅវត្តជ្រៃធំក្បាលគោឆ្ងាយ ឪយកទៅផ្ញើនឹង ផ្ញើសង្ឃរាជៗ វត្ត ។

សេងគា ៖ មិញស្រុកកំណើតអ៊ំនៅភូមិ?

ថា ៖ ភូមិស្រែខ្លាយ ។

សេងគា ៖ ឃុំ?

ថា ៖ ឃុំអន្លង់កែវ ស្រុកទ្រាំង ។

សេងគា ៖ អ៊ំរៀនពេលរហូតដល់ថ្នាក់ទី៩នឹងទៅក៏រដ្ឋប្រហារមក?

ថា ៖ រដ្ឋប្រហារ ។

សេងគា ៖ រដ្ឋប្រហារមក អ៊ំក៏ឈប់ទៅ ឬក៏ទៅណាទៀត?

ថា ៖ ឈប់ៗមិនបានម៉ាខែ ប្រហែល២ខែ ចូលធ្វើរំដោះនឹងគេទៅ ។

សេងគា ៖ កាលហ្នឹងអ៊ំអាយុប៉ុន្មានហើយ?

ថា ៖ ១៨ ។

សេងគា ៖ ទៅក៏ចូលធ្វើទ័ពទៅ?

ថា ៖ ទៅនឹងគេ ទៅជីវីរមាល ។

សេងគា ៖ ទ័ពខាងណា ខាងលន់ នល់ ឬក៏ខាងខ្មែរក្រហម?

ថា ៖ ខាងខ្មែរក្រហម ។

សេងគា ៖ កាលនឹងចូលធ្វើទ័ពនៅណា?

ថា ៖ ធ្វើមុនដំបូងនៅទ័ពខេត្តៗតាកែវ ។

សេងគា ៖ កាលនឹងគេឲ្យនៅរៀនប៉ុន្មានថ្ងៃដែរ បានអាចគេបញ្ជូនមក?

ថា ៖ កាលនឹងនៅតូច ចេះឆ្ងាយមក ចេះរត់តាមគេ គេឲ្យមកជីវីរមាល គេឲ្យរៀនសូត្រ ដឹងរៀនស្អីណា ។

សេងគា ៖ កាលនឹងទៅទ័ពនឹងទៅម្នាក់ឯងទេ ឬក៏មានមិត្តភ័ក្រអីទៅជាមួយដែរ?

ថា ៖ មាន ទៅជាមួយគ្នាហូរហែ ។

សេង៉គា ៈ មានឈ្មោះអីខ្លះ?

ថា ៈ អឺ! ឈ្មោះពេញជី មិនដឹងអាណាអាណែខ្លះ ឥឡូវអាខ្លះស្លាប់អស់ ឃើញរស់នៅខ្ញុំអាទៅជាមួយគ្នានឹង។ ភ្លេចមែនស្លាប់តាំងពីកំពុងវៃគ្នាផង ស្លាប់អាមកផ្ទះវិញ អានឹងនៅជាមួយគ្នាស្លាប់នឹងយើងទៀត។

សេង៉គា ៈ កាលនឹងទៅប៉ុន្មាននាក់ ដែលអ៊ំចូលធ្វើទ័ពនឹង?

ថា ៈ ខ្ញុំទៅមុនដំបូងតែ២នាក់ ឥឡូវស្លាប់ហើយជីដូនមួយ ប៉ុន។

សេង៉គា ៈ អ្នកស្លាប់នឹងឈ្មោះអីគេ ជីដូនមួយនឹង?

ថា ៈ សឿន ឈ្មោះសឿន ចន សឿន វាចេះ។

សេង៉គា ៈ ស្លាប់កាលសង្គ្រាមនឹង?

ថា ៈ បាទ! កាលសង្គ្រាមវៃនៅកោះអណ្តែត។ កាលនឹងទ័ពគេមានចូលមកហូរហែកាត់ផ្លូវអន្លក់វនឹងចូលដំរីរមាលរត់តាមគេវាអីចឹង។ វាក្មេង ហើយដល់ឲ្យទៅនៅនឹងចូលបានកន្លះគេមានបញ្ជូនមកធ្វើទ័ពធ្វើអីចេះរត់តាមគេទៅ។

សេង៉គា ៈ អីចឹងរត់តាម មុនដំបូងមកពីខេត្ត ហើយទៅភ្នំដំរីរមាល?

ថា ៈ អត់ទេ រត់តាមគេទៅលើ គេប្រមូលផ្តុកម្ខាំងអាធំៗអី យុវជននារីអីទៅតាមគេ បានទៅព្រៃដំរីរមាលលិចនឹង វាក្មេង។ ដល់ទៅនៅនឹងបានកន្លះខែ គេមានបញ្ជូនឲ្យមកធ្វើទ័ពធ្វើអីចេះរត់តាមគេ។

សេង៉គា ៈ រត់តាមមុនដំបូងមកពីខេត្ត ហើយទៅភ្នំដំរីរមាល?

ថា ៈ អត់ទេ រត់តាមគេទៅលើសិន។

សេង៉គា ៈ រត់តាមគេសិន?

ថា ៈ ប៉ុនគេប្រមូលផ្តុកម្ខាំងអាធំៗអីយុវជន យុវនារីអីទៅតាមគេ។

សេង៉គា ៈ មកបានឡើងមកខេត្ត?

ថា ៈ បានទៅព្រៃដំរីរមាលៗលិច ដល់ទៅនៅនឹងបានប្រហែលកន្លះខែ ២០ថ្ងៃអីចឹងទៅនៅពួក នឹងអ្នកធំៗគេបញ្ជូនរត់តាមគេធ្វើទ័ព ចុះមកវៃ រត់តាមគេមក។

សេង៉គា ៈ ចុះវៃដំបូងនៅណាៗ?

ថា ៈ ចាប់ផ្តើមដំបូង?

សេង៉គា ៈ បាទ!

ថា ៈ ចាប់ផ្តើមដំបូងពួកខ្ញុំវៃនៅទួលព្រៃសណ្តែក ល្វេ។

សេងគា ៖ ព្រៃអីគេ?

ថា ៖ ព្រៃសណ្តែក ល្វេយើង ។

សេងគា ៖ ព្រៃសណ្តែក ល្វេ?

ថា ៖ ស្រុកព្រៃសណ្តែក ស្រុកទ្រាំងមិញនឹង អានឹងក្បាលដំបូងនេះដំបូង មិនវ៉ៃប៉ុនឆ្នក់នាយអាយមុនដំបូងនឹង ។ ប៉ុនខ្ញុំមិនបានឆ្នក់ទេ ឲ្យនៅក្រោយដូចខ្ញុំថាមុនដំបូងរត់តាមគេនឹង ។

សេងគា ៖ នៅព្រៃល្វា?

ថា ៖ ផ្សារល្វេ ព្រៃសណ្តែកៗស្រុកទ្រាំងនឹង ។

សេងគា ៖ ដល់ពេលវ៉ៃនឹងរួចហើយ អ៊ំទៅណាទៀត?

ថា ៖ ដល់វ៉ៃហើយនៅ វ៉ៃបណ្តើររៀនសូត្របណ្តើរ កាលនឹងមិនវ៉ៃដាប់ទេ វ៉ៃឆ្នក់នាយអាយមកហាត់ទៀត ។ ដូចថាវ៉ៃនៅល្វេ មកសម្រាកនៅបារាយណ៍ចុងលិចអីចឹង ហាត់រៀនបណ្តើរ ។

សេងគា ៖ កាលនឹងឪពុកម្តាយអ៊ំនៅផ្សេងទេ អ៊ំមកតែឯងជាមួយមិត្តភ័ក្រ្តទេ?

ថា ៖ បាទ!

សេងគា ៖ កាលអ៊ំមកចូលធ្វើទ័ព រត់តាមគេនឹង មកតែ២នាក់មិត្តភ័ក្រ្ត ជីដូនមួយទេ?

ថា ៖ តែ២នាក់ជីដូនមួយនឹង ។

សេងគា ៖ ម៉ែឪនៅផ្ទះនោះ?

ថា ៖ នៅ ម៉ែឪនៅផ្ទះ ។

សេងគា ៖ ហើយបន្ទាប់មកទៀត អ៊ំក្រោយពីវ៉ៃនៅលន់ នល់នឹងវ៉ៃបានប៉ុន្មានឆ្នាំ?

ថា ៖ វ៉ៃទល់៧៥ទល់ចប់ អឺ!ទល់៧០មកទល់៧៥ខែ៧បានខ្ញុំចុះមកផ្ទះ វ៉ៃរហូត ។

សេងគា ៖ អ៊ំនៅធ្វើទ័ពនឹង កាលនឹងប្រយុទ្ធជាមួយនរណាគេ ទាហានវៀតណាម ឬមួយទាហានលន់នល់?

ថា ៖ ជាមួយធៀវគឺ ជាមួយលន់ នល់ ទាហានខ្មែរក្រហមមិនប្រយុទ្ធជាមួយលន់ នល់ ។

សេងគា ៖ នៅផ្សារល្វេ ព្រៃសណ្តែងនឹងរួច អ៊ំទៅណាទៀត?

ថា ៖ វ៉ៃម៉ាជួរនឹងរហូតដល់ធ្លាយភ្នំដិន អានឹងគេហៅទ័ពខេត្តទី១ ទ័ពខេត្តវ៉ៃក្នុងខេត្តទាំងមូល ។

សេងគា ៖ ចុះអ្នកដែលជ្រើសរើសអ៊ំឲ្យធ្វើទាហានឈ្មោះអីគេ?

ថា ៖ អាជ្រើសរើសធ្វើទាហាន គិតទៅមិនដឹងជាអាណាជាអាណែចេះទៅៗ ។

សេងគា ៖ ចុះអ៊ំអត់ស្គាល់មេគេមកប្រជុំ?

ថា ៖ ស្គាល់មេ ប៉ុនដល់មេអាមេនឹងបានន័យថាដូចខ្ញុំថា គេប្រមូលផ្តុំបានទៅដូចថាឈ្មោះក ដូចថាឥឡូវឈ្មោះសារី គេប្រមូលផ្តុំ បានន័យថាខ្ញុំទៅតាមឈ្មោះសារី ។

សេងគា ៖ មេរបស់អ៊ំឈ្មោះសារី?

ថា ៖ ការប្រមូលផ្តុំរត់ឡើងឈ្មោះសារី ។

សេងគា ៖ ចុះពេលធ្វើកាន់ជាប់ជាមួយអ៊ំឈ្មោះអី?

ថា ៖ កាន់ជាប់ជាមួយខ្ញុំឈ្មោះ សឿន នៅខេត្តតាកែវ ទ័ពខេត្ត ។

សេងគា ៖ ឥឡូវគាត់ស្លាប់ ឬរស់ហើយ?

ថា ៖ ដឹងស្លាប់រស់ទេ គេនៅព្រៃមិនដែលសួរដំណឹង ។ ប៉ុនគេថា កាលនឹងចេះទៅដល់ខ្មែរក្រហមនឹង គាត់មិនធ្វើកងពលធំ នាំមានរឿងជាមួយខ្មែរក្រហមរត់ចូលប៉ារ៉ាកាលនេះបាត់ខ្លួនរហូតហ្នឹងសឿននឹង ។

សេងគា ៖ ដល់ពេលរត់បាត់ទៅ មានអ្នកណាគេឡើងជំនួសគាត់ទៀត?

ថា ៖ ហីលែងដឹង ខ្ញុំគ្មានដឹងអានេះដំណឹងទេអារត់បាត់នឹង ខ្ញុំនៅនេះនឹង ។

សេងគា ៖ អ៊ំម៉ាកងពលរបស់អ៊ំមានគ្នាប៉ុន្មាននាក់?

ថា ៖ វរសេនាតូចមុនដំបូងម៉ា-គ ។

សេងគា ៖ ម៉ា-គ មានប៉ុន្មាននាក់?

ថា ៖ ម៉ា-គ កាលដំបូង១០០ជាង ១៥០នឹងកើតដំបូង ។

សេងគា ៖ ចុះ ក ខ គ ខុសគ្នាម៉េច?

ថា ៖ ខុសគ្នា ដូចថាម៉ាក្រុម១២នាក់ អានឹងខគេហៅអនុសេនាតូចមាន៣០-៤០នាក់ ។

សេងគា ៖ ចុះបើម៉ា-ក?

ថា ៖ ម៉ា-គ ។

សេងគា ៖ ក អត់មានទេ?

ថា ៖ អត់មានទេ ។

សេងគា ៖ មានតែ ខ?

ថា ៖ បាទ! ក ខ គ ។

សេងគា ៖ ក-ប៉ុន្មាននាក់?

ថា ៖ ក មើលគេហៅក្រុមហើយនឹងខ ក-ក្រុម ។

សេងគា ៖ ក-ក្រុម ម៉ាក្រុមមានប៉ុន្មាននាក់?

ថា ៖ ១២ ហើយដល់ខ ៣៦-៤០ ។

សេង៉គា ៖ ចុះ គ?

ថា ៖ គ ១២០ឡើង វាមានមេធំមេអី ។

សេង៉គា ៖ ចុះ ឃ?

ថា ៖ ឃ អានឹងចប់សិន បានគេរៀបវរសេនាតូច វរៈសេនាធំទៀត ។

សេង៉គា ៖ ចុះមាន ងទៀត?

ថា ៖ ង។នឹងវរសេនាធំ ។

សេង៉គា ៖ ហ្នឹងមានប៉ុន្មាននាក់រាប់ពាន់?

ថា ៖ វរសេនាធំមាន៣-៤៣ាន់នាក់ បាទ!អានឹងរៀបពេញមិនពេញ អានឹងក៏មាន៨០០ដែរ មានឈ្មោះ ។

សេង៉គា ៖ នៅពេលដែលនៅផ្សារល្វេ និងព្រៃសណ្តែកនឹង រួចហើយគេបញ្ជូនឡើងមកណាទៀត?

ថា ៖ ឈប់ៗខ្ញុំនិយាយប្រវត្តិដែលធ្វើ ទី១ទ័ពតំបន់គេហៅទ័ពតំបន់នៅក្នុងខេត្តតាកែវ វ៉ៃនៅសមរភូមិជុំវិញ កន្លែងណាក៏អាចទៅវ៉ៃបានដូចជា អង្គតាសោម ដូចជាតាកែវ ដូចជាតាកែវ ដូចជាបារាយណ៍...ជុំវិញខេត្តតាកែវ ។ ដល់ក្រោយមកឆ្នាំប៉ុន្មាន ឡើងទ័ពភូមិភាគ បានន័យថាវ៉ៃក្នុងខេត្តប៉ុន្មានខេត្តនឹង ខេត្តកំពង់ស្ពឺ ខេត្តកំពត ខេត្តតាកែវ ចូលដល់ខេត្តកណ្តាលខ្លះអីចឹងទៅ អានឹងនិយាយពីប្រវត្តិ ។

សេង៉គា ៖ ដល់វ៉ៃទាំងអស់ ទ័ពទាហានរបស់អ៊ំវ៉ៃបានគ្រប់ខេត្ត?

ថា ៖ បាទ!អានឹងពេលគេត្រូវការគេហៅ ដូចថាអានឹងឥឡូវត្រូវការទៅវ៉ៃកំពត គេឲ្យទៅកំពត ។

សេង៉គា ៖ អ៊ំឡើងទៅទ័ពភូមិភាគនៅឆ្នាំណាកាលនឹង?

ថា ៖ ឈប់រកនឹកសិន មិនភ្លេចទេចាំ កាលជិនាន់អាបេវ៉ៃខ្លាំង៧៣ ។

សេង៉គា ៖ ៧៣?

ថា ៖ ៧៣អាបេវ៉ៃខ្លាំង ។

សេង៉គា ៖ ៧៣ កាលនឹងអ៊ំមានអាយុដូចជា១៧ ១៨?

ថា ៖ អូ! ប្រើងនិយាយធ្វើស្អី គិតមើលចូល១៧មែន ។

សេង៉គា ៖ បាទ!១៧ ព្រោះអី១៨ ហើយគាត់ឥឡូវ ៧៣?

ថា ៖ ១៧មែន អានឹង ។

សេដគា ៖ អ៊ំធ្វើការរយៈពេល២-៣ឆ្នាំ អ៊ំមានឡើងសក្តិឡើងអីទេ?

ថា ៖ អត់ទាន់ឡើងទេ ។

សេដគា ៖ អ៊ំនៅកូនក្រុមធម្មតា?

ថា ៖ ធម្មតា ព្រោះចេះឡើងណាយើងនៅក្មេង មិនបានទៅរៀនគេប៉ុន្មាន អ្វីៗតាមក្រោយគេ ជួនកាលផ្ទុះបាយ ។

សេដគា ៖ ពេលនឹងកាលនឹង ហូបចុកអីធម្មតា?

ថា ៖ ធម្មតា ប៉ុនបើវ៉ៃ គេថាធម្មតាកថាបាន ជួនកាលពោតសំឡី ពោតអីទៅ ។

សេដគា ៖ ឡើងទ័ពភូមិភាគដូចឆ្នាំ៧៣?

ថា ៖ បាទ! ហ្នឹងហើយ ។

សេដគា ៖ បន្ទាប់មកទៀត អ៊ំធ្វើអីទៀត?

ថា ៖ នៅភូមិភាគរហូត ។

សេដគា ៖ ភូមិភាគនៅម្តុំណា?

ថា ៖ ភូមិភាគបានន័យថាភូមិភាគនារតីទិស ខេត្តកំពត តាកែវ កំពង់ស្ពឺ ។

សេដគា ៖ នៅចល័តអីចឹង ទ័ពនឹង?

ថា ៖ បាទ!

សេដគា ៖ ទ័ពនឹងអត់មានកន្លែងបញ្ឈរជើងចុះនៅកន្លែងណាទេ?

ថា ៖ អត់ទេ ។

សេដគា ៖ កន្លែងភូមិភាគអ៊ំនឹង ទ័ពមានប្រហែលជាប៉ុន្មានពាន់នាក់ ប៉ុន្មានរយនាក់?

ថា ៖ មើលប៉ុន្មានកងពល មុនដំបូងមានម៉ាកងពល កងពលដើមភ្លេចទៀត ។

វ៉ាស៊ី ៖ ៧០៣?

ថា ៖ មិន លេខ៣ក្រោយបំផុត ។

វ៉ាស៊ី ៖ ៧០៣?

ថា ៖ មិនទេ ៧០៣ពួកភូមិភាគពិសេស ។ ប៉ុនពួកខ្ញុំកាលដំបូងគេហៅកងពលទី២ ដល់ក្រោយមកកងពល២១០ភ្លេចអីចឹង កាលដំបូង ។ ដល់គេបែកក្នុងភូមិភាគមាន៣កងពល កងពលទី២ មុនដំបូង ។

សេដគា ៖ កាលនឹងប្រធានកងពលឈ្មោះអីគេ?

ថា ៖ ប្រធាន តាប៉ិតនឹងមុនដំបូង ។

សេងគា ៖ ស្ទីប៊ិត?

ថា ៖ ហ៎! មិនដឹងស្ទីប៊ិត ។

រ៉ាស៊ី ៖ សម ប៊ិតនឹង មែនទេ?

ថា ៖ ហ្នឹងហើយ សម ប៊ិត លើកក្រោយឡើងគណៈភូមិភាគ ។

រ៉ាស៊ី ៖ ហ្នឹងឡើងក្រោយគេ?

ថា ៖ បាទ! កាលនឹងគាត់ប្រធានកងពលមុនគេនឹង នៅនារតីនឹង ហើយតាវ៉ែម ២នាក់នឹង ។

សេងគា ៖ គាត់នឹងជាមនុស្សម៉េចដែល គាត់កាច ឬស្លូតទេ?

ថា ៖ នៅចាំ កាច យើងថាគាត់ស្លូត ប៉ុនបើមតិខ្លះថាកាច បើមិនដែលមានបញ្ហាអីផង ធ្វើតាមគម្រោងផែនការដាក់ចុះមក ។

សេងគា ៖ ចុះអ្នកធ្វើខុស គាត់មានធ្វើបាបអីទេ?

ថា ៖ រឿងការងារធ្វើខុស វាមានគេហៅមកចូលមន្ទីរអប់រំអប់អីចឹងដែរ ឬគេបញ្ជូនមកភូមិភាគមក ។

សេងគា ៖ ចុះអ្នកដែលហៅមកមន្ទីរអប់រំ មានពេលទៅវិញអត់?

ថា ៖ មានច្រើនទៅវិញដែរនឹង គេហៅមកដាក់កន្លែងមន្ទីរកងពលណែនាំ កុំឲ្យវាសេរី កុំអីពេក ។

សេងគា ៖ អ៊ំនៅរហូតដល់៧៨ ហើយ៧០ប៉ុន្មាន?

ថា ៖ នៅដល់៧៩នឹង រត់មកវិញនឹង ។

សេងគា ៖ នៅភូមិភាគនឹងរហូត?

ថា ៖ នៅរហូត ។

សេងគា ៖ ចុះអ៊ំឡើងសក្តិនៅឆ្នាំណាដែលឡើងសក្តិបន្តទៀត?

ថា ៖ ខ្ញុំឡើងកាលនេះខ្ញុំនៅរហូតរំដោះហើយបានឡើង ។

សេងគា ៖ រំដោះ៧៥បានឡើង?

ថា ៖ បាទ! បានឡើងសក្តិនឹងគេ អ្នកខ្លះគេមានប្រវត្តិ ។

សេងគា ៖ បានឡើងសក្តិអីគេ ពីមុនអ៊ំធ្វើអីទាហានធម្មតាទេ?

ថា ៖ ទាហានធម្មតាទេ ។

សេងគា ៖ ពលទោធម្មតាទេ?

ថា ៖ បាទ!

សេងគា ៖ បន្ទាប់មកទៀតឡើងសក្តិ ៗ អីគេ?

ថា ៖ ឡើងបានបញ្ជាការ គ ។

សេងគា ៖ បញ្ជាការ គ?

ថា ៖ នេះដោយសារខ្ញុំក្មេងខ្ចីបានគេក្រឲ្យឡើង ហើយម្យ៉ាងការផ្លាស់ប្តូរនិន្នាការ ដកសក្តិគាឡុង ដាក់ព្រៃក្តួច ខ្ញុំឡើងមកណាអីចឹងទេ កុំអីមិនងាយបានឡើង ព្រោះ ។

សេងគា ៖ ដកអ្នកណាគេចេញ?

ថា ៖ អឺ! ដករាប់មិនឈ្នះទេ អាអ្នកដក ៗ ងាប់បាត់អស់ទៀតហើយ គេថានិន្នាការមិនល្អកាលនឹងគេមិនដកពេលវា ។ មេ១០ មេ៥០ខ្វងកុំនិយាយ ពាក់ព័ន្ធហើយបងធ្វើប៉ូលីស ៗ សក្តិ៣នៅសៀមរាប ប៊ុនឥឡូវ៧៥រំដោះមកខ្ញុំបាញ់ចោល ៗ នៅកំពង់ឆ្នាំង ។

សេងគា ៖ ឡើងប្រធាន-គ កាន់ទាហាន១០០នាក់ជាង?

ថា ៖ ១០០នាក់ជាង ទាហាននឹងលែងគ្រប់ហើយ សល់ពីសង្គ្រាមប៉ុន្មានទៅប៉ុននឹង ប៉ុនច្បាប់វាអីចឹង ។

សេងគា ៖ កាលពេលកាន់ប្រធាន-គនឹង អ្នកណាគេអ្នកឲ្យអ៊ំឡើង?

ថា ៖ ឈ្មោះ សឿន ៗ និយាយមិញ សឿនថាប្រធានតំបន់ ។

សេងគា ៖ ម៉េចបានគាត់ឲ្យឡើង?

ថា ៖ មូលហេតុឡើងអានឹងការងារគេចាត់តាំងតាមលំដាប់ថ្នាក់ពីលើមក ។

សេងគា ៖ ឃើញអ៊ំធ្វើការងារល្អ ឬក៏ម៉េចទេ?

ថា ៖ អានឹងបើមិនល្អ គេមិនឲ្យឡើង ក្បួនគេអីចឹង ។

សេងគា ៖ ឃើញអ៊ំធ្វើការងារល្អ គេឲ្យឡើងទៅ?

ថា ៖ ហើយយើងរៀងដើងចាស់ដែលហើយ វាក្របានឡើង ។

សេងគា ៖ ដល់ពេលអ៊ំឡើងហើយ អ៊ំទៅកាន់នៅកន្លែងណា?

ថា ៖ កាលនឹងថាឡើងមុនដំបូងមកធ្វើអាផ្លូវលេខ៣នឹង នៅបកក្រោយនៅផ្លូវលេខ៣ ។

សេងគា ៖ ផ្លូវលេខ៣ ភូមិអី ឃុំអី?

ថា ៖ នៅធ្វើចំការដូងស្លាគូនឹង មុខថ្នល់ ហើយដល់ចុះពីថ្នល់មកឲ្យនៅក្នុងកាហាង ៗ ព្រំដែន ។

សេងគា ៖ កាហាង ស្លាគូ ឃុំអី?

ថា ៖ ដឹងឃុំអីបៀតស្រុកជន ដាក់ចំការដូងស្លាគូ ។

សេងគា ៖ ចំការដូងស្លាគូ?

ថា ៖ ហ្នឹង អានឹងធ្វើថ្នល់ម៉ាដូរពីថ្នល់បត់អន្លង់វែង សោម លុបថ្នល់លុបអី ហើយដឹកដីរកៅស៊ូតាំងពីស្រែក្នុងយកមកចាក់ធ្វើនឹង ។ ហើយដល់រួចពីនឹង មកឲ្យចុះមកការពារព្រំដែននៅកំពង់ក្រសាំង កាហាងនេះ ។

សេងគា ៖ បាទ! ការពារកំពង់ក្រសាំង កាលនឹងចូលដាប់៧៥?

ថា ៖ ៧៦ហើយ ។

សេងគា ៖ ៧៦?

ថា ៖ បាទ! ៧៦ ។

សេងគា ៖ ការពារនឹងរហូត ។ ចុះក្រៅពីដូចថា មុនដំបូងក្រោយពីការដែលដូចជាចាក់ថ្នល់ចាក់កៅស៊ូ ហើយបន្ទាប់មកទៀត ការពារនឹង គឺមានប្រយុទ្ធតទល់ជាមួយខាងៗទាហានអីគេទាហាន វៀតណាម?

ថា ៖ ជាមួយវៀតណាម អានឹងការពារគ្រាន់ទៅទេ អត់មានប្រយុទ្ធទេ ទៅនឹងដូចថាមានធ្វើស្រែប្រាំងធ្វើអីទៀត គេឲ្យធ្វើហើយវាមានវ៉ៃ ។ កាលកាច់បង្គោលរបងម្តងហើយក្រោយមកបានវ៉ៃចប់នឹង ។ កាលនឹងយើងមិនកាចបង្គោលរបងម្តងឆ្នាំ៧៦ ខែប៉ុន្មាន ហើយដល់ក្រោយមកបានវ៉ៃទ័ពពី៧៧ ដាក់គ្នាដាប់ ។

សេងគា ៖ ដល់ពេលអ៊ំនៅនឹងរហូតបានៗប្រពន្ធ ឬម៉េច ឬមកណា ការប្រពន្ធ?

ថា ៖ ការប្រពន្ធ៧៧ នៅស្អី ។

សេងគា ៖ នៅជិតព្រំដែន នៅកន្លែងក្រសាំង?

ថា ៖ ពោធិ៍ខ្វិត ។

សេងគា ៖ ទៅពោធិ៍ខ្វិតវិញ?

ថា ៖ ពោធិ៍ខ្វិតនឹងដឹង ។

សេងគា ៖ អ៊ំចេញពីកំពង់ក្រសាំងបានប៉ុន្មាន?

ថា ៖ វាចេះ ទ័ពណាវាចល័តចុះចល័តឡើង ជួនកំពង់ក្រសាំង ជួនយុក្កា ជួនមកទីទន្លេបាក់សាក់អានេះគេហៅគេបួរ ។

សេងគា ៖ អ៊ំអ្នកបញ្ជាឲ្យអ៊ំដូរអីដាក់បេសកកម្មឲ្យអ៊ំធ្វើ គេមានសរសេរជាលិខិត សរសេរអីផ្ញើមកទេឲ្យដូរឲ្យអីទេ?

ថា ៖ បេសកកម្មនៅក្រសួង គេចេញបេសកកម្មមិនបាច់មានលិខិតទេ គ្រាន់ថាលើបញ្ហាមានប៉ុន្មានខ្ទួយកតាមគ្នា ។

សេធគា ៖ គេអត់មានយកលិខិតអីមកឲ្យអីមួយទេ?

ថា ៖ អត់ទេ ហើយបានគេបញ្ជាតាមតេអូនេះទៅ ។

សេធគា ៖ កាលនឹងគេប្រើតាមតេអូ?

ថា ៖ តេអូដែរ ។

សេធគា ៖ អត់ដែលប្រើតាមសំបុត្រ?

ថា ៖ សំបុត្រកាលនៅវៃជាមួយលន់ នល់ប្រើ វៃជាមួយយួនលែងហើយ ប្រើដុំៗជាមួយលន់ នល់ បើជាមួយយួនឈប់ហើយ ។

សេធគា ៖ អីនៅចំការដូង ស្វាគូបានប៉ុន្មានខែ បានដូរទៅកំពង់ក្រសាំង?

ថា ៖ យី! នៅម៉ាប្រាំង មិននឹងដឹងប៉ុន្មានខែ ។

សេធគា ៖ ម៉ាប្រាំងប្រហែលកន្លះឆ្នាំ?

ថា ៖ មិនដល់ទេ ដូចថាមើលកាលនឹងវាត្រៀមនឹងគេទេ ហើយចេះនៅជាប់ទៅគ្រាន់រំដោះភ្លាម មក ឲ្យមកសម្រាកនឹង ហើយដល់សម្រាកនឹងគោលការណ៍គេឲ្យធ្វើលុបដូវ គេត្រៀម គោលការណ៍គេប្រាប់ឲ្យត្រៀមកម្លាំង ក្រែងលអាមេរិចកាំងវៃបកតាមកំពង់សោម ទប់ កម្លាំងជំនួយនឹង ឲ្យត្រៀមនៅនឹង ដូចការពាររបងភ្នំពេញ ។ ហើយបានឲ្យជួយលុបថ្នល់ លុបអីផង ។ ហើយដល់វាស្ងប់ស្ងាត់សភាពការណ៍គេបញ្ជូនឲ្យមកនៅព្រំដែននេះវិញ ។

សេធគា ៖ តែម៉ារយះ?

ថា ៖ បាទ! ម៉ារយះខ្លីដែរ ប៉ុន្មានខែដើមឆ្នាំ ។

សេធគា ៖ ទាល់ទៅកំពង់ក្រសាំងនៅយូរ?

ថា ៖ កំពង់ក្រសាំងនៅយូរ ប៉ុនប្តូរចុះប្តូរឡើងនៅភ្នំដិន ដូរវិល ។ ម៉ាវរសេនាតូចគេអត់ឲ្យនៅ ឈរជើងដដែលៗទេ គេឆ្លាត គេខ្លាចនៅឈរជើងដដែល ក្រែងយើងពាក់ព័ន្ធសន្តិសម្ព័ន្ធ ជាមួយវៀតណាមអីចឹង គេត្រូវដូរមិនមែននៅនឹងទេ ។ បើវរនេះនៅប៉ុននឹងខែៗមិនមែន ឲ្យយើងបោះទីតាំងរាប់ឆ្នាំទេ ខ្លាចគេថាសន្តិសម្ព័ន្ធ ត្រូវជាមួយវាយួន នៅឲ្យតែដឹកមែនឲ្យ ស្រីស្អាតមកមែន ។

សេធគា ៖ កាលនឹងធ្លាប់ឲ្យអីដែរ?

ថា ៖ ហ៉េ! ឲ្យ គេឲ្យប៉ុនយើងមិនយក ចុះនោះនៅត្រូវគ្នាតើ មិនទាន់បាញ់គ្នាផង ។ ហើយកាល ណាហ៊ានធ្វើពួកនឹង ងាប់ហើយ លែងរស់ដល់ឥឡូវហើយ ។

សេធគា ៖ គ្រាន់ការពារ ប៉ុន្តែត្រូវគ្នា?

ថា : ត្រូវ មុនដំបូងត្រូវ ហើយយួនចេះ ផ្តល់ឲ្យស៊ីចុកស្រេច ហើយយើង អានឹងគេហៅសតិសម្ព័ន្ធ ហើយបើយើងលង់លក់ ប៉ុនបើលែងស៊ីដឹកមិនសូវអីទេ បើលែងយកស្រីទៀតគ្មានរស់ផាប់ហើយ បើស៊ីដឹកធម្មតាទេ គ្រាន់ថាយើងកុំក្លាំងពេក ។

សេងគា : ស៊ីដឹកអត់អី តែហ៊ានរកស្រីដឹងថាស្លាប់?

ថា : ស្លាប់អត់នៅទេ ។

សេងគា : អ្នកណាអ្នកមកសម្លាប់ យួន ឬម្នាក់ស្រីនឹងទេ ដែលមក?

ថា : សម្លាប់ មេខ្មែរក្រហមបាញ់ចោល ។

សេងគា : ខ្មែរក្រហមដឹងថាយកស្រីវៀតណាមមក ដឹងថាបាញ់ចោល?

ថា : អឺ! ហ្នឹងហើយ ។

សេងគា : ចុះអ៊ីធ្លាប់មានខាងយើង ទាហានៗដែលធ្លាប់យកស្រីនឹងមក ឃើញមេខ្មែរក្រហមមកបាញ់ចោលអីចឹងទេ?

ថា : អត់ទេ កន្លែងខ្ញុំអត់មាន បើកន្លែងគេមាន វរៈខ្ញុំអត់ ។

សេងគា : ម៉េចបានអ៊ីដឹងថាកន្លែងគេមាន?

ថា : ដឹង ប៉ុនមិនដឹងអ្នកណាអ្នកណែ យើងមិនបានទៅឃើញឈ្មោះ ឃើញអី ។

សេងគា : ចុះអ៊ីដឹងតាមអ្នកណាគេ ដឹងថាកន្លែងគេមាន?

ថា : ដឹងតាម ពូនិយាយគ្នាតៗគ្នាវរៈនេះ គេយកបាញ់ចោលលេងស្រីយួន គេថាវរៈ-ក ដឹងអ្នកណាយកបាញ់អ្នកណាឈ្មោះអី ។ មិនងាយទេទ័ព តាមដានមិនដឹងទេ កន្លែងណានៅកន្លែងនឹង មុននឹងទៅដល់ប្រាប់គ្នា មុនទៅលេងគ្នានឹង ដល់ប្រាប់ការងារត្រូវសម្លាប់ត្រូវអីនឹង មិនងាយបានដឹងឈ្មោះ ដឹងតែដំណឹងទេ អាចពូតាមខ្យល់ទេ ។

សេងគា : អីចឹងអ៊ីនៅត្រពាំងក្រសាំង បានប្រហែលជិតម៉ាឆ្នាំ?

ថា : មិនដល់ ដូចខ្ញុំថាគេដូរគេមិនឲ្យនៅយូរទេ ។ ប៉ុនឥឡូវខ្ញុំប្រាប់ឲ្យស្តាប់ ដូចមុខសញ្ញាភ្នំដិនត្រូវដូរ ពោធិ៍សង្កែ កំណប់ យុថ្កា ដើមត្រសេក ថ្មពាដុំ កាហាង កំពង់ក្រសាំង ។

សេងគា : ចុះអ៊ីបានប្រពន្ធ បាននៅកន្លែងណា?

ថា : នៅកន្លែងព្រៃតាម៉ៅ ។

សេងគា : ព្រៃតាម៉ៅ?

ថា : ព្រៃតាម៉ៅ ភ្នំដិន ។

សេងគា : ព្រៃតាម៉ៅ ភ្នំដិន?

ថា : បាទ! ផ្ទះនៅនឹង ។

សេងគា : កាលនឹងអ្នកណាគេអ្នករៀបចំឲ្យអ៊ំ?

ថា : ឋានៈគេវរសេនាធំ គេរៀបឲ្យនឹង ត្រូវសម្រេចពីកងពលមក អាឈាង ឈ្មោះឈាង ស្លាប់ហើយ ។

សេងគា : ឈាងនឹងធ្វើអី?

ថា : ឈាងនឹង វរសេនាធំ អានឹងមុននឹងនេះគេសម្រេចពីកងពលមកឲ្យរៀបឲ្យ ។

សេងគា : រៀបឲ្យកាលនឹងមានប៉ុន្មានគូ?

ថា : ប៉ុន្មាន៦ ។

សេងគា : សុទ្ធតែមេកងពល?

ថា : ទេ! អាខ្លះអនុវរសេនាតូច អនុសេនាធំ ។

សេងគា : ហើយរៀបការគេធ្វើម៉េចខ្លះ កាលនឹង?

ថា : កាលនឹងគេគ្រាន់ហៅមកអង្គុយទន្ទឹមគ្នា មានធ្វើស្អី ហើយប្រកាសឲ្យទទួល ។

សេងគា : ហើយស្គាល់គ្នាពីមុនមកទេ?

ថា : អត់ ។

សេងគា : ហើយគេរៀបឲ្យមានប្រកែកមានអីទេ?

ថា : ខ្ញុំគេឲ្យដើររកដែរ តែរកមិនត្រូវ ដល់គេយកឲ្យមកឃើញត្រូវ គ្មានទេ ។

សេងគា : ដល់គេយកឲ្យត្រូវ?

ថា : បាទ! ការជិនាន់នោះគ្មានអ្នកណានៅមួយ ស្លាប់អស់ហើយ ។

សេងគា : សល់តែអ៊ំ អ្នកផ្សេងស្លាប់អស់?

ថា : បាទ! ៦នាក់អស់រលីង ។

សេងគា : កាលនឹងមានស្គាល់ ការជាមួយអ្នកណាខ្លះ?

ថា : នៅខ្ញុំមួយ ។

សេងគា : មានស្គាល់ទេ?

ថា : ជីមិនស្គាល់ ។

សេងគា : អ្នកណាឈ្មោះអីខ្លះ?

ថា : មើលដែលអាឆេន ប្តីផុននេះ អាភ៊ាន់ អាសេង ណាមួយទៀត ៥នាក់ស្លាប់អស់ហើយ នៅខ្ញុំមួយ៦ ។

សេង៉គា ៖ ហេតុអីបានពូដឹងថាស្លាប់?

ថា ៖ ទៅស្រុកក្រោម អាមួយមកពីលើឈើ នៅកំពង់ធំនេះ ។

សេង៉គា ៖ អីចឹងស្លាប់សម័យប៉ុលពតទាំងអស់?

ថា ៖ អាវ៉ាន់ប្ដីប្រពន្ធនឹងមួយ នឹងការដំណាលគ្នា ឈើដែរ មិនស្រុកក្រោមទេ កាលនេះទៅស្រុកក្រោម ។

សេង៉គា ៖ ហើយការជាមួយគ្នានៅជាមួយគ្នារហូត ឬមានបែកគ្នា?

ថា ៖ អត់ទេ ការហើយគ្មាននៅជាមួយគ្នា កង់ខុសៗគ្នា ប៉ុន្តក្នុងវរសេនាធំជាមួយគ្នា ។

សេង៉គា ៖ គេឲ្យនៅជាមួយគ្នាបានប៉ុន្មានថ្ងៃ បានបែកគ្នា ការហើយ?

ថា ៖ ទាំង៦នាក់នឹង?

សេង៉គា ៖ អត់ទេ ជាមួយប្រពន្ធអ៊ំ?

ថា ៖ អឺ! គ្មានកំណត់ទេ ស្រេចយើងគេថាសមរភូមិនៅការពារឃ្លួនប្រហែលជាពគីឡូ ស្រេចយើងមកហើយប្រាប់គេ ប៉ុន្តគ្រាន់ថាវ៉ា ។

សេង៉គា ៖ ហើយប្រពន្ធពូធ្វើអីដែរ?

ថា ៖ កាលនឹងមុនដំបូងទៅនេះទៅ ទៅពីនារីស្រុកទៅស្នាក់ការ១ ។

សេង៉គា ៖ ពូដឹងថាមូលហេតុអីបានគេចាប់គូផ្ទឹមពូជាប្រពន្ធអ៊ំ?

ថា ៖ គេមូលហេតុគេចង់និយាយចេះ គេថា ម៉ែឪទុកមួយលើ មានដែលអង្គការដែលជាអ្នកគ្រប់គ្រងអនាគតរបស់ខ្លួន ឲ្យអង្គការគេអ្នកចាត់ចែង ។ កាលនឹងគេនិយាយល្ងង់ជាងខ្ញុំគេមិនសូវនិយាយអីចឹង ។

សេង៉គា ៖ ឈោងអីអ្នកចាត់ចែងឲ្យទាំងអស់?

ថា ៖ ឈោងគ្រាន់តែបទបញ្ជាពីកងពលមកទេ ព្រោះខ្ញុំវរសេនាតូចដែរ បើវរសេនាធំដល់មានបញ្ជាពីកងពលមក គេមិនបានមកគេឲ្យវ៉ាធ្វើទៅ ។ អានឹងដល់ចាប់ផ្ទុំ ។

សេង៉គា ៖ បន្ទាប់ពីការរួចអស់ហើយ បែកគ្នាទៅធ្វើការកន្លែងផ្សេងទៀត?

ថា ៖ បាទ!

សេង៉គា ៖ ហើយពូមានឡើងបុណ្យសក្តិអីទៀត?

ថា ៖ ឡើងម៉ា ឡើងទៀត ។

សេង៉គា ៖ កាលឡើងៗនៅឆ្នាំប៉ុន្មាន?

ថា ៖ ឡើងអា៧៧ ។

សេង៉គា ៖ ៧៧ទៀត?

ថា ៖ បាទ!

សេង៉គា ៖ ៧៧ ឡើងបានប៉ុន្មានកាំ?

ថា ៖ ៧៧ឡើងបានបញ្ញាការវរសេនាធំ។ ចាំបាច់លាក់អីប្រវត្តិរូបសួទ្រាំងត្រង់ ខ្ញុំធំ ខ្ញុំចុះមកវរសេនាធំ ចុះមានអ្នកណារកប្រវត្តិរូប សាលក្រមនៅមេធំៗ ខ្ញុំមានលាក់ណាចេញទៅប្រវត្តិរូបខ្ញុំចេញតាំងពីយូរ។

សេង៉គា ៖ ពេលការហើយ ឡើងបុណ្យសក្តិ ឬក៏មិនទាន់ការទេឡើង?

ថា ៖ ការហើយយូរដែរ។

សេង៉គា ៖ ការហើយបានប៉ុន្មានខែបានឡើង?

ថា ៖ អឺ!ការ ឡើងបាន៣ខែ យួនវ៉ៃបែក ឡើងបានបញ្ញាការវរសេនាធំ។

វ៉ាស៊ី ៖ វរសេនាធំលេខប៉ុន្មាន?

ថា ៖ លេខ១៣ កងពិសេស។

វ៉ាស៊ី ៖ ក្នុងកងពលប៉ុន្មាន?

ថា ៖ កងពលលេខ២១០ អានឹងប្រវត្តិមុនដំបូងនៅវរសេនាតូចលេខ៣៦០ វរសេនាធំ១៨ កងពល២១០។

វ៉ាស៊ី ៖ មិនមែន៣១០?

ថា ៖ ២១០។

សេង៉គា ៖ វរសេនាតូច២៦០?

ថា ៖ ៣៦០។

សេង៉គា ៖ វរសេនាធំ២១០?

ថា ៖ អឺ! វរសេនាធំ១៣០ អឺ!វរសេនាធំលេខ១៣ ដល់កងពល២១០អានឹងក៏អីចឹង។

សេង៉គា ៖ កងពល២១០?

ថា ៖ វរសេនាធំលេខ១៣។

សេង៉គា ៖ ចុះម៉េចបានគេឲ្យឡើងទៀត?

ថា ៖ អានឹងដោយសារគិតទៅ អាមុនវាងាប់ទៅ អាក្រោយវ៉ៃគួរសមទៅ គេឲ្យឡើងទៅអានឹង ឆ្លើយតែប៉ុននឹង វាគ្មានសូកប៉ាន់ជំនាន់ប៉ុលពតនឹង។

សេង៉គា ៖ អ្នកណាគេឲ្យឡើង ឈាននឹងដដែល?

ថា ៖ អត់ទេ កងពល អានឹងកងពលធំចាត់ចែង ។

សេងគា ៖ កងពលធំឈ្មោះអី?

ថា ៖ កាលជំនាន់នឹងលួនចុះមិនដឹងអ្នកណា ខ្ញុំភ្លេចទៀត ។

សេងគា ៖ គេប្រជុំគ្នាគេប្រកាសឲ្យឡើង ឬក៏ម៉េច?

ថា ៖ បាទ! ប្រកាស ព្រោះកាលនោះនៅសមរភូមិជួនកាលកុន មួយដាប់ទៅឲ្យឡើងបណ្ដោះអាសន្ន បញ្ហាតាមគេអូក៏បាន ឲ្យឡើងជំនួសបញ្ហាបន្ត ប្រថុចញ៉ុច ។

សេងគា ៖ កាលនឹងកំពុងបាញ់គ្នាខ្លាំង បានឲ្យឡើង ឬក៏ម៉េច?

ថា ៖ អឺ! រៀបចំកម្លាំងវ៉ៃបាញ់ខ្លាំង ឡើងទៅចេះអានឹងខ្ញុំរៀបចំកងអន្តរាគមន៍ថ្មី ។

សេងគា ៖ កាលនឹងគេហៅឡើងសក្តិនឹង គេហៅនៅកន្លែងណាភ្នំដិនដែរ?

ថា ៖ នៅនេះចេះ នៅទេពប្រណម ភ្នំរន្ទះ ។

សេងគា ៖ ទេពប្រណម?

ថា ៖ កាលនឹងសៀននឹងដដែល មែនសៀនមកពីបូព៌ា មកពីពាយ័ព្យ ទេពប្រណម ។

សេងគា ៖ ទេពប្រណមឃុំអីគេ?

ថា ៖ ទេពប្រណម រន្ទះៗ អង្គប្រាសាទ ។

សេងគា ៖ អង្គប្រាសាទយើងនេះ?

ថា ៖ បាទ! អង្គប្រាសាទយើងស្រុកគីរីវង់ដែរ ។

សេងគា ៖ បន្ទាប់ពីឡើងរហូតនឹងមក វ៉ៃហ្នឹង មានវ៉ៃបាក់ទ័ព វ៉ៃអីទេកាលនឹង?

ថា ៖ អឺ! បាក់រាល់ដង ម្តងគេម្តងយើង ។

សេងគា ៖ កាលនឹងមានដូចថា អ៊ំធ្វើវរសេនាធំ ឬវរសេនាតូចអីចឹង មានចាប់បានពួកវៀតណាម ពួកឈ្លើយសឹកអីមកទេ?

ថា ៖ ចាប់ ។

សេងគា ៖ ចាប់បាន?

ថា ៖ បាទ!

សេងគា ៖ ចាប់បាន អ៊ំឲ្យកូនចៅអ៊ំធ្វើអីដែរកាលនឹង យកទៅណា?

ថា ៖ ចាប់បានបញ្ជូនមកឲ្យភូមិភាគវា ។

សេងគា ៖ ភូមិភាគហ្នឹង មេៗធំឈ្មោះសៀននឹង?

ថា ៖ អត់ទេ ភូមិភាគកាល តាម៉ុកវិញ តាម៉ុកភូមិភាគនារតីមុនដំបូង ។

សេធំកា ៖ អីចឹងបញ្ជូនឲ្យតាម៉ុកនឹងម៉ន?

ថា ៖ បញ្ជូនតាមខ្មែរ មកកងពលតូចៗ គេឡើងមកកងពលធំៗ គេបញ្ជូនមកតាម៉ុក ។

សេធំកា ៖ ចុះកាលឡើង៧៧នឹង មែនតាម៉ុកអ្នកកាន់កាប់ទេ?

ថា ៖ ហ្នឹង ។

សេធំកា ៖ ភូមិភាគហ្នឹង មិនមែនតាម៉ុកអ្នកតែងតាំងអីទេ កាលនឹង?

ថា ៖ មើលឈប់ តាម៉ុកដឹងទៅដើងហើយ ឬនៅកាលនឹង នៅទេ!តាម៉ុកក្រែងទៅតាំងពីមុន ៧៩ ទៅលេងនឹងបន្ទាយ តាម៉ុកគេយកឯងដាក់ខាងជើងស្រុកឃ្លូននោះ ។ ជំនាន់តាប៉ិតទេ ក្រោយទេ នៅនឹងតាប៉ិត ចេញទៅបានតាប៉ិត ។

សេធំកា ៖ តាម៉ុកចេញទៅបានតាប៉ិត?

ថា ៖ បាទ! តាម៉ុកចេញ តាប៉ិតជំនួស ។

សេធំកា ៖ អីចឹងតាប៉ិតអ្នកដំឡើងសក្តិអី?

ថា ៖ ហ្នឹងហើយកាលនឹងមានតាប៉ិត ព្រោះមេភូមិភាគ ពីព្រោះតាម៉ុកចេញហើយ ខ្ញុំបញ្ជា ក្រោយតាប៉ិត អានឹងខ្ញុំស្រពេចស្រពិលទៀត វាភ្លេច ប៉ុនកាលនឹងតាម៉ុកចេញហើយ កាលជំនាន់នឹង ។

សេធំកា ៖ ចុះអីដែលបានជួបតាម៉ុកផ្ទាល់និយាយជាមួយគាត់ទេ?

ថា ៖ កាលសង្គ្រាមលន់ នល់ដែលជួប ។

សេធំកា ៖ កាលពេលខ្មែរក្រហម អត់ដែលជួបទេ?

ថា ៖ អត់ទេ ។

សេធំកា ៖ អត់ដែលជួបសោះ?

ថា ៖ បាទ! ជួបដែល ពេលជួបពីចំងាយ គេនៅលើវេទិការមកប្រជុំកំពង់អំពិល ១៧មេសា ឃើញ ។ ហើយបើកាលជំនាន់វៃលន់ នល់ ខ្ញុំនៅព្រៃក្មេងត្រពាំងត្រុំនឹង ខ្ញុំនៅការពារនៅ វៃនឹង គាត់ឆ្លងចុះឡើងទៅកំពង់ស្ពឺ អឺ!កំពង់ឆ្នាំង ថីមិនឃើញ ។

សេធំកា ៖ ដែលនិយាយលេងជាមួយអីទេ?

ថា ៖ អត់ទេ និយាយលេងអីគេគ្រាន់ប្រាប់ ទោះបីកូនទាហានមេទាហានយើងមិនថាៗធ្វើចេះៗ ដូនណែនាំយើងលេង ។ ហើយចំពោះការឆ្លងចុះឆ្លងអី គេមិនយកកម្លាំងខ្ញុំប្រើទេ កម្លាំងខ្ញុំ នៅផ្ទាល់ជាមួយគេនោះ គេគ្រាន់ឲ្យយើងនាំអែបជាមួយ គេមិនទុកចិត្តយើង ។

សេធំកា ៖ កាលអីធ្វើកងវរសេនាធំនឹង មានកូនចៅក្រោមបង្គាប់អីៗនៅចាំឈ្មោះទេ?

ថា ៖ អឺ! ថឺមិនចាំ ចាំមេខ្វះ អាពីសាចអីស្គាល់ តូចៗមិនស្គាល់វាក្មេងអស់ ។

សេងគា ៖ ចាំបានប៉ុន្មាននាក់ដែរ មើលទៅអាចរាប់បានខ្វះទេ?

ថា ៖ អានឹងវានៅក្នុងវរៈជាមួយគ្នាៗមើល គិតទៅពិបាកនិយាយដែរ អានឹងវាបត់បែនចេះបាន...ឧទាហរណ៍ក្នុងម៉ាចំណោមអន្តភាពទី១ក្នុងវគ្គ ក្នុងខេត្ត ទី២ក្នុងភូមិភាគ បើនិយាយទៅវាឡប់មុខឡប់ក្រោយ ការស្គាល់នឹងក៏អីចឹងដែរ ។ កាលនៅក្នុងតំបន់ មេធំជាងគេសឿន ហើយបន្ទាប់ពីសឿនមក ដែល ។

សេងគា ៖ ប្រធានភូមិភាគឈ្មោះប៊ិត?

ថា ៖ មិនទេ ក្រោមៗសឿននឹងទៀត មុនដំបូងនិយាយក្នុងខេត្ត ហើយដល់អីចឹងវាស្លាប់អស់សឿន សុច ហើយតាសារី ដែលអាបេវើងាប់នៅនេះ អាជើងចាស់ៗនឹង ដូចតាម៉េងអានឹងយើងនិយាយក្នុងខេត្ត ។ ហើយយើងឡើងទៅភូមិភាគមានដូចថាមេធំខាងលើ មេកងពលធំមុនដំបូងសឿន វ៉ែម ប៊ិតអីចឹង ។ ហើយដល់ក្រោយមកវរសេនាធំមានឈ្មោះរឿន ឈ្មោះសម្បត្តិ ឈ្មោះឡេន ហើយដល់វរសេនាតូចមានឈ្មោះចន ឈ្មោះស៊ីៗ វាពិបាកនិយាយ ការនិយាយឡប់ចុះមកក្រោម ។

សេងគា ៖ ចុះជីដូនមួយអ៊ំកាលនឹងស្លាប់ៗនៅឆ្នាំណា ដែលទៅជាមួយនឹង?

ថា ៖ អឺ! ស្លាប់នៅកោះអណ្តែត នៅឆ្នាំប៉ុន្មានទេកាលវ៉ៃនៅកោះអណ្តែតនៅក្នុង៧២ ។

សេងគា ៖ ៧២ នៅលន់ នល់នៅឡើយ?

ថា ៖ អឺ! លន់ នល់ ពេញដីង ៧២ ។

សេងគា ៖ ចុះអ៊ំឡើងជាកងពលធំ?

ថា ៖ អត់ទេ មិនមែនកងពលធំណា វរសេនាធំ ។

សេងគា ៖ វរសេនាធំកាន់ទ័ពប៉ុន្មាននាក់?

ថា ៖ តាមក្បួន ម៉ាវរសេនាធំវាត្រូវមាន៣-៤ពាន់ ប៉ុនទ័ពខ្ញុំកាលនឹងមិនមានដល់២ពាន់ រៀបចំកងពិសេសថ្មី ។

សេងគា ៖ ហើយអ្នកក្រោមអ៊ំ២-៣នាក់អ៊ំអត់ចាំទេ?

ថា ៖ អានឹងមេៗធំជាងខ្ញុំ គេប្រធានដែលឈ្មោះអី ។

សេងគា ៖ អត់ចាំទេ?

ថា ៖ ឈប់ មេខ្លួនឯងមិនចាំនឹកសិន កុំឲ្យអន់ពេក អឺ!បើខាននឹកអីចឹង កាលនឹងឋានៈ...បញ្ជាការតូចជាងស្នងការ ហើយស្នងការខ្ញុំឈ្មោះ មិនមែនថាមិនស្គាល់ៗជាមួយគ្នាតាំងពីយូរ

ដល់នេះក្មេចទៅ តាំងពីមិនទាន់នៅវរសេនាធំជាមួយគ្នា ។ ហើយបើផ្ទះៗដឹងនៅស្វាយអញ្ជិត កំពង់ស្ពឺ ។

សេងគា : គាត់នៅរស់?

ថា : យី! មិនដឹងគេនៅរស់ម៉េចទេ មិនដែលដឹងដំណឹងយូរហើយ ។

សេងគា : អីចឹងអ៊ំអត់ចាំ រកនឹកអត់ឃើញ?

ថា : យ៉ើ! និយាយទៅអន់ពេកឈ្មោះមេខ្លួនឯងអត់ចាំ ។

សេងគា : អត់អីរឿងនឹងវាយូរហើយ ៣០ឆ្នាំជាងហើយ ធ្វើម៉េចនឹកអត់ឃើញក៏អត់អីដែរ ព្រោះអី វាយូរហើយ ។

ថា : មិនមែនទេ ចង់នឹកឲ្យឃើញ ព្រោះវាអត់ពេក ម៉េចនឹកមិនឃើញធ្វើមេសោះ ។ ៣២ឆ្នាំទើបនៅជាមួយគ្នាបែកគ្នាកាល៧៩ ។

សេងគា : ៧៩មកឥឡូវ ។

ថា : មាន ឈ្មោះមាន ។

សេងគា : អ៊ំនឹកឃើញមាន ។

ថា : ងាប់មិនងាប់មិនដឹង មិនដែលឮឈ្មោះនឹងក្រោយមកតាំងពី៧៩មក ។

សេងគា : មាន គាត់នឹងមេបញ្ជាការធំ?

ថា : អឺ! គេស្នងការ ធំគេវរសេនាធំរបស់គេ អ្នកចាត់ចែងមេ ។

សេងគា : អ៊ំភាគច្រើនដូចទាហានវៀតណាម ចាប់បានខាងយើងញឹកញាប់ទេ ទាហានខ្មែរយើង?

ថា : មិនដែលនឹងចាប់បានខ្ញុំនឹង ។

សេងគា : ដូចទាហានវៀតណាមចាប់ទាហានយើងអី?

ថា : អូ! ត្រង់នឹង បើវាចាប់បានមិនសូវមាន បើវាបាញ់ៗស្លាប់ច្រើន ។

សេងគា : ចាប់បានបាញ់ចោល វៀតណាម?

ថា : អត់ទេ យើងមិនឲ្យចាប់ ។

សេងគា : យើងបាញ់តរហូតវាបាញ់ស្លាប់?

ថា : បាញ់ស្លាប់ ។

សេងគា : ប៉ុន្តែយើងចាប់បានខាងវាច្រើន?

ថា : អត់ទេ អត់មានដូចគ្នា យូរៗ មិននេះវាដាច់ខាតដូចគ្នា រកចាប់ ។

សេងគា : ចុះអ៊ំថាចាប់បានបញ្ជូនមកភូមិភាគៗ?

ថា ៖ ចាប់ ហ្នឹងកាលនឹងចាប់បានប៉ុន្មាន ចាប់បានម្ដង ។

សេងគា ៖ ចាប់បានប៉ុន្មាននាក់ដែរកាលនឹង?

ថា ៖ បាន២នាក់ ។

សេងគា ៖ ចាប់បាន២នាក់ ទាហាននឹងជាទាហានអីគេ ទាហានធម្មតាទេ ឬទាហានអីគេវៀតណាមនឹង?

ថា ៖ ទាហាននឹងចេះទេកុំអីចាប់មិនបានទេ ដាក់ច្រវ៉ាក់ៗវាបាញ់ទៅអស់គ្រាប់ចាប់បានៗ បើតាមនេះវាត្រូវបាញ់ចោល មិនបាច់យកទៅ គ្រាន់បញ្ហាពីលើកុំឲ្យបាញ់ឲ្យយកទៅ ដល់នេះមិនបាច់យកទៅផង ព្រោះគោលការណ៍មិនបាច់ឲ្យចាប់ ឲ្យកំទេចឲ្យតែពេលបាន ដូចថាបានអីចឹង ឈ្លើយរស់ គេបញ្ជាមិនបាច់សម្លាប់ ឲ្យយកគេ ។

សេងគា ៖ ហើយពេលដែលចាប់បាន មានធ្វើបាបធ្វើស្អី?

ថា ៖ គ្មានធ្វើស្អីតែអីចឹង មានតែបញ្ជូនទៅ ព្រោះវាដឹងកាន់កាំភ្លើងដឹងធ្វើអី ដល់បាញ់វាចោលតែម្ដង ហើយបើមិនឲ្យបាញ់ មានធ្វើអី គ្រាន់ចងបញ្ជូន ។

សេងគា ៖ មានវ៉ៃខ្លះបញ្ជូនអី?

ថា ៖ យោធាអីចឹង បំរុងមិនទុកមិនបាច់វ៉ៃឈឺសាច់ បាញ់ចោលទៅ ទម្រាំឲ្យគេបញ្ជូនទៅវ៉ៃធ្វើអីចងឲ្យតែជាប់ទៅ ។

សេងគា ៖ ចុះអ៊ំតទល់នឹងរហូតមានបាក់ទ័ពបាក់អីរត់ចេញពីនឹងកាលនឹង?

ថា ៖ អឺ! បាក់ទ័ពបាក់ឡើងដូចទឹកជោរហើយនាចអីចឹង ។ ខ្ញុំវ៉ៃម៉ាដូរ ក្រោយ៧៩មកវ៉ៃម៉ាដូរនឹងរហូតទល់យើងឆ្ងាយត្រែងត្រយឹងផ្លូវលេខ៤ ទម្រាំចុះមកនឹង ។

សេងគា ៖ អ៊ំកាលដែលចាប់បានទាហានវៀតណាមនឹង ចាប់បាននៅម្ដុំណាកាលនឹង?

ថា ៖ ចាប់បាននៅម្ដុំកាលខាងកើតក្រពៅ ។

សេងគា ៖ ខាងក្រពៅ ភ្នំដិននឹង?

ថា ៖ បាទ! អាម្ដុំប៉ម ។

សេងគា ៖ ទាហាន២នាក់នឹងដាច់ដោយឡែកបែកទ័ព ឬម៉េច ២នាក់ចាប់បាន?

ថា ៖ គេនៅដាក់ច្រវ៉ាក់នៅនឹងជើង ដាក់កាំភ្លើងនៅពីលើ ។

សេងគា ៖ ដល់ដាច់ដោយឡែកអីចឹងបានចាប់បានអស់គ្រាប់?

ថា ៖ មិនទេ គេបាក់ទ័ពនៅវាល ។

សេងគា ៖ អីចឹងពេលដែលអ៊ំចាប់អីចឹង រយៈពេលប៉ុន្មានបានចាប់បានបែកដល់៧៩ បានវ៉ៃបែក?

ថា ៖ បាទ!

សេងគា ៖ បន្ទាប់ពីអីចាប់ទាហាននឹងបញ្ជូនទៅឲ្យគេហើយ ប៉ុន្មានខែទៀតបានបែក ប៉ុន្មានឆ្នាំទៀតបានបែក?

ថា ៖ អឺ! កាលនឹងដឹងវគ្គមុន វគ្គក្រោយភ្លេចទៀត វាវ៉ៃខ្លាំង ២វគ្គទេ ៧៧មួយ ៧៩មួយ ។

សេងគា ៖ កាលចាប់បាន៧៩ ឬ៧៧?

ថា ៖ បើមិន៧៧ វាភ្លេចដូចខ្ញុំថានិយាយទៅវាចាំហើយៗ ប៉ុនមិនដឹងពិតប្រាកដថាថ្ងៃនេះ ថ្ងៃនោះ ខែនេះខែនោះ វគ្គប៉ុន្មាន ។

សេងគា ៖ អុំគ្រាន់ប្រហែល បើចាំមិនច្បាស់ទេ ប្រហែលជិតៗនឹង?

ថា ៖ វាការងារធ្លាប់ធ្វើវាគ្រាន់នៅចាំ ចាំខ្លះ ចាំហើយមិនដឹងមុខដឹងក្រោយ ។

សេងគា ៖ អុំការហើយប្រពន្ធអត់នៅជុំគ្នាទេ?

ថា ៖ អត់ទេ បានអីនៅជាមួយគ្នា ។

សេងគា ៖ អីចឹងបានអត់ទាន់មានកូន ដល់ពេលយូរហើយ ។ អុំពេលដែលបែក នៅនឹងរហូតដល់បែក ៧៩មកនឹង អុំកាលនឹងវ៉ៃបាក់ទ័ពប៉ុន្មានដងដែរ ដែលយើងវ៉ៃ វៀតណាមវ៉ៃបែករត់?

ថា ៖ អឺ! ច្រើនលើក ច្រើនសារ កាលនៅក្រប៉ៅរត់ទៅមកមិនដឹងប៉ុន្មានសារ វ៉ៃចូលលេខបានត្រឹមដំណាក់ព្រៃសប្បាយ កំពង់ទ្រេ ទៅវិញទៅមក ។

សេងគា ៖ ហើយពួកទ័ពដូចអុំ នៅនឹងហូបបាយហូបទឹកយ៉ាងម៉េច កងទ័ពអស់អីទាំងអស់គ្នា?

ថា ៖ ដាំបាយដាក់ស្នុក ដាក់កាតាទៅ ។

សេងគា ៖ កាលនឹងហូបបាយ អត់មានបបរទេ?

ថា ៖ អត់បបរទេ ។

សេងគា ៖ ហើយចុះកន្លែងសម្រាកអីម៉េចដែរ?

ថា ៖ កន្លែងសម្រាកៗតាមភូមិ តាមផ្ទះ តាមព្រៃ មានអង្រឹងមួយ តង់មួយ ។

សេងគា ៖ ចុះពេលរបួសអីមានពេទ្យមានអីតាមទេ?

ថា ៖ មានពេទ្យតាមកង ។

សេងគា ៖ ហើយចាំពេទ្យនឹងខ្លះទេ ពេទ្យនឹងអ្នកណាគេខ្លះសម្រាប់ព្យាបាលទាហានអីនឹង?

ថា ៖ ពេទ្យតាមកងចាំៗខ្លះអត់ខ្លះ ។

សេងគា ៖ ឈ្មោះអីខ្លះ?

ថា ៖ មើលតាមកងខ្ញុំធ្លាប់នៅ អាខ្លះពេទ្យវរសេនាធំ អាខ្លះពេទ្យវរសេនាតូច អឺ!ឈ្មោះអឹម ។

សេងគា ៖ ឈ្មោះអីមរស់ប្រុស្លាប់ឥឡូវ?

ថា ៖ អឺ! មិនដឹងរស់ស្លាប់ទេ មិនដែលជួបគ្នានឹង ហើយគាសេង ។

សេងគា ៖ សេងរស់ហើយស្លាប់?

ថា ៖ មិនដឹងនៅកោះអណ្តែតនោះ ហើយគាស្អីមួយទៀតទេនៅ ។

សេងគា ៖ ពេលដែលអ៊ំបែកទ័ពដូចថាវៀតណាមវ៉ៃចូល កាល៧៩នឹងអ៊ំនៅណា?

ថា ៖ អឺ!

សេងគា ៖ កាល៧៩នឹងអ៊ំនៅណាកាល៧៩ ពេលវៀតណាមវ៉ៃបែក?

ថា ៖ ពេលមកវិញ?

សេងគា ៖ បាទ! ៧៩នឹង?

ថា ៖ មកវិញនៅនឹង ។

សេងគា ៖ អ៊ំបាក់ទ័ពពីកន្ទែងភ្នំដិនមកនឹង?

ថា ៖ អត់ទេ កាលបកពីលើមកវិញ ចាំមើលដល់ពេលខ្ញុំមកនឹង ខ្ញុំចុះមកដោយខ្លួនឯង ។

សេងគា ៖ ពេលទប់ទល់នឹងទ័ពអត់បាននាំគ្នារត់?

ថា ៖ ចុះមកផ្ទះ ។

សេងគា ៖ កាលនឹងរត់ប៉ុន្មាននាក់ រត់មកទ័ពនឹង?

ថា ៖ មកគ្នា៣នាក់ ។

សេងគា ៖ ៣នាក់នរណាខ្លះ?

ថា ៖ ជាមួយមាននឹង ជាមួយវ៉ាន់ ហើយខ្ញុំ ។

សេងគា ៖ វ៉ាន់នឹងធ្វើអីដែរ?

ថា ៖ វ៉ាន់នឹងគេវរសេនាតូចដែរ ។

សេងគា ៖ អីចឹងនាំគ្នាទាំង៣នាក់បាក់ទ័ពរត់មកចោលកូនទាហានទៅ?

ថា ៖ បាទ! វាដាច់គ្នាអស់ហើយចេះមកៗ មិនថានយោបាយវាមិនធ្វើអីមកៗ ។

សេងគា ៖ រត់ពីណាមកហ្នឹង?

ថា ៖ ចុះមកតាមភ្នំខាងលិច ។

សេងគា ៖ ភ្នំដីវិរមាល?

ថា ៖ ហ្នឹងដីវិរមាលមក ដើរកាត់ដីវិរមាលមកចុះមកកាត់ៗចូលផ្ទះៗប្រពន្ធនេះមឿងចារ ។

សេងគា ៖ មកទាំង៣រស់ទាំង៣នាក់?

ថា ៖ អត់ទេ អាមួយមកឈឺងាប់ អាវ៉ាន់ ហើយមាននឹងដឹងនៅរស់ទេ មិនដែលសួរដំណឹងយូរហើយ មានការងាររអីត្រូវសួរវ៉ាអត់ ។

សេងគា ៖ ដល់ពេលរត់មកជួប វៀតណាមអត់មកតាមរកអីអីទេ?

ថា ៖ អត់ទេ ។

សេងគា ៖ ដល់ពេលរត់មកជួប វៀតណាមអត់មកតាមរកអីអីទេ អឹមានលាក់ឈ្មោះលាក់អីដែលអត់កាលនឹងវៀតណាមចូលមក?

ថា ៖ អត់លាក់ទេ ចាំមើលកាលខ្ញុំមកដល់មុនដំបូង វ៉ាមិនមែនអត់ មកមុនដំបូងចូលផ្ទះខ្ញុំនៅអង្គកែវ ដល់ចូលខ្ញុំមកដល់ផ្ទះបាន៣យប់ មកញាក់បណ្តើរ ដែលខាងនគរបាលស្រុកគេមកហៅទៅសាលាស្រុកនៅព្រៃសណ្តែកនេះ ។

សេងគា ៖ គេហៅទៅធ្វើអី?

ថា ៖ ហៅទៅសាកសួរពីការចុះមក ហើយឃុំនៅនឹងទៅ ឃុំនៅនឹង៧ខែ ហើយបាន១មកនឹង ។

សេងគា ៖ ឃុំអឹំនៅនឹង?

ថា ៖ អឺ! ឃុំទុក ។

សេងគា ៖ ឃុំទុក?

ថា ៖ ឃុំអត់ឲ្យ ។

សេងគា ៖ ឃុំគេដាក់នៅកន្លែងណា?

ថា ៖ ដាក់នៅសាលាស្រុកទ្រាំង ។

សេងគា ៖ អានឹង៧៩?

ថា ៖ ៧៩ រដ្ឋកម្ពុជាធំ ។

សេងគា ៖ បាទ! រតពី?

ថា ៖ រត់ពីខ្មែរក្រហមមក ឃុំទុកនឹងមិនមែនគេដាក់ច្រវ៉ាក់អីទេ គេផ្ញើនៅជាមួយលោកមេស្រុកនៅជាមួយយោធាម៉ង គ្រាន់យើងគ្មានសិទ្ធិដើរទៅណាចេញឆ្ងាយ ចេញឲ្យប្រាប់គេ ។ អានឹងទៅណាក៏វិន័យ ទៅបានតែ៣ខែ មកលេងផ្ទះបានក៏សុំ ហើយចង់ទៅមើលល្ខោនមើលឡាំអីសុំគេ១ឲ្យទៅ អានឹងគិតទៅដូចជាផ្ញើប៉ុលសារឿន អ្នកផ្ញើឲ្យនៅជាមួយប៉ុលសារឿន ។

សេងគា ៖ អានឹងបែក៧៩ ហួស៧៩មករាហើយ?

ថា ៖ ហួសហើយ ។

សេងគា ៖ គេឃុំជាប់នឹងទៅ?

ថា ៖ គ្មានសួរអីផង គេអត់សួរសួរ គេបញ្ឈាក់ពីប្រវត្តិហេតុការណ៍តស៊ូរដ្ឋកម្ពុជា ខាងនេះហើយ នឹងការតស៊ូរបស់ខ្មែរក្រហម ហើយឲ្យយើងផ្ដាច់លះបង់ចិត្តគំនិតតាមខ្មែរក្រហមទៀតទៅ ឲ្យតាមរដ្ឋាភិបាលថ្មីនឹងទៅ ។ ហើយអីចឹងគេទៅ ឲ្យនៅមើលឲ្យយើងចូលធ្វើទ័ពខ្ញុំអត់ធ្វើទៀត ហៅធ្វើវិញដែរ ។

សេងគា ៖ ហៅអុំធ្វើទ័ពវិញ?

ថា ៖ ហៅ ។

សេងគា ៖ តែអុំអត់ធ្វើ?

ថា ៖ អត់ធ្វើនឹកឃើញខ្ជិលធ្វើ ចាំនៅរកស៊ី បើតាមក្ដៅចិត្តត្រូវធ្វើ ប៉ុនដល់នឹកឃើញវាមិនចេះអក្សរមិនធ្វើ គ្នាមិនចេះអក្សរធ្វើស្រុកឯករាជ្យគេទាត់ចោលទៀតហើយ ។ ហើយបើធ្វើអាចស្លាប់ ការនឹងវៃជាមួយខ្មែរក្រហម បើធ្វើ.................. ។ ខ្ញុំមិននិយាយចំ ប្រវត្តិវាល្អអាក្រក់ ប៉ុនការបាញ់បោះក្នុងសង្គ្រាម ខ្ញុំមិនមានការគុំរួសគំរើយហួសប្រមាថគេបាញ់ឃើញនៅមុខមាត់អីខ្លះយោធាគេមាន អាពួកកងពលថ្មីៗ ជូនបាញ់កូនទាហាននៅនឹងមុខក៏មានដែរ កងពលខ្ញុំចាស់ធ្វើអត់បាន គេថាមានការសម្រេចពីភូមិភាគ ។ ហើយដាក់ស្ដែងនេះកងពល២៥០ ហ៊ានបាញ់កូនចៅចោលនៅនឹងវាលកងពលថ្មី ។ ហើយពួកខ្ញុំនិយាយអត់អួត អត់ឲ្យប្រព្រឹត្តអីចឹង ប៉ុនអានេះគេថាថ្មីដល់គំរាមបន្តិចទើបខ្លាច ហើយចាស់ខ្លាចផុះ ឡើងស្លាប់ គេចាស់ដឹងវិន័យជាង អីចឹងដល់ធ្វើតាមច្បាប់ ។

សេងគា ៖ ចុះកាលអុំរត់ទៅពេលណាបានជួបប្រពន្ធកូនវិញ?

ថា ៖ ចុះមកជួប ។

សេងគា ៖ មិញគេរត់តែ៣នាក់ទេ ប្រពន្ធមកដែរ?

ថា ៖ ប្រពន្ធគេមកមុន២-៣ថ្ងៃ អានឹងមិនមែនមូលគ្នាទេ ប៉ុនគ្រាន់មកជួបគ្នានៅផ្ទះដដែល ។

សេងគា ៖ ជួបនៅអន្លង់វែង?

ថា ៖ បាទ! ៣នាក់ជួបទាំង៣មកទាំងអស់គ្នា គ្រាន់ប្រពន្ធមកមុន ។

សេងគា ៖ កាលដែលគេមកអុំទៅកន្លែងស្រុកកន្លែងអីនឹង អ្នកណាគេអ្នកមកហៅដែលហៅសួរចម្លើយអីចឹងនឹង?

ថា ៖ កាលនឹងប្រធានស្រុក ។

សេងគា ៖ ប្រធានស្រុកឈ្មោះអីគេ?

ថា ៈ ប្រធានស្រុកកាលនឹង សុខ សារុន ។

សេងគា ៈ សុខ សារុន?

ថា ៈ អឺ! សុខ សារុន ហើយស្រី សារឿន សុខ សារុន តាមកធ្វើប្រមុះនៅឃុំកំពែងផ្កាយ ប្រមុះ គេចៅហ្វាយស្រុក ហើយអនុប្រធានស្រីសារឿន ។ ហើយខ្ញុំនៅជាមួយគេផ្ទាល់ គេផ្ញើថាខ្ញុំជាប់...ប្រធាន-គ-ស្រុកឈ្មោះវ៉ាត ខ្ញុំនៅជាមួយគេ នគរបាលឈ្មោះ នេត សេង ។

សេងគា ៈ កាលនឹងគេសួរច្រើនទេ គេសួរប្រវត្តិរូប?

ថា ៈ អត់ទេប្រវត្តិរូបថីមិនសួរ សួរការពិតគេមិនសួរ គ្រាន់គេឲ្យយើងនិយាយពីការងាររស់នៅ ការងារបង្ហាន: ប៉ុនការពិតប្រាកដដឹងមុន ព្រោះកូនចៅចុះមុននិយាយប្រាប់អស់ហើយ ដូច យើងនិយាយអស់មានអីសួរ ព្រោះគេដឹងប្រវត្តិមុនៗនឹងមកមុននឹងមកនឹង ព្រោះកូនចៅ នៅជាមួយខ្ញុំមកខ្លះអី សួរមេឯងឈ្មោះអី មេឯងកាចស្លូត ឈ្មោះអីយើងនិយាយតាម ដំណើរគេចាប់បានលែងសួរហើយ ហើយទាំងអស់មិនបាច់ទៅនៅមើលគេមើលឯងនឹង ។

សេងគា ៈ តែអ៊ំអត់នៅ?

ថា ៈ អត់ទេ នៅ អាជាប់... ។

សេងគា ៈ ជាប់បានប៉ុន្មានខែ?

ថា ៈ យូរដែរ៧ខែ ប៉ុន៧ខែការពិតតាមលាក់ដើង ព្រោះបើក....កុំនិយាយរឿងនឹងពិបាកដែរ ត្រូវឲ្យរួចមុនឲ្យមកទាំងយូរ ។ ប៉ុនគ្រាន់នៅដូចនៅដើរលេង ប៉ុនការនឹងកំពុងអត់គ្រាន់បើ ដែរ នៅលីអង្ករបានអង្ករយកមកហូប អង្ករពោតសំឡី អង្ករ លីអង្ករឡានកាកបាទ ក្រហមមក ។

សេងគា ៈ កាលអ៊ំនៅនឹងមានជួបហេតុការណ៍នេះ អ៊ំគិតថាគួរឲ្យរន្ធត់ ធ្វើអីទេនៅនឹង?

ថា ៈ បើខ្ញុំរន្ធត់មានតែប៉ុននេះទេ ពេលរន្ធត់ខ្លាំង ពេលគេរៀបចំដកកម្លាំង ពួកនិន្នាការយកមក ព្រៃក្តួច ហើយនឹងភ្នំសំឡុង ខ្ញុំស្លុតខ្លាំងកន្លែងនឹងទេ ។ បើដោយខ្សែកសង្គ្រាមរឿងធ្វើ សង្គ្រាមអានឹងវារន្ធត់ញាក ការរន្ធត់ការបាក់ទ័ព ការធ្វើបេះបញ្ឈាមកមិនពេញចិត្តខ្លះអីចឹង អានឹងរន្ធត់ខ្លាំងក្រោយរំដោះ ការផ្លាស់ប្តូរដកព្រៃស្តួច ភ្នំសំឡុង អានឹងភ្ញាក់ផ្អើលខ្លួនឯង ចង់ងាប់ហើយ ។

សេងគា ៈ ចុះអ៊ំនៅពេលដែលអ៊ំ កំឡុងពេលធ្វើការទាហានខ្មែរក្រហមរហូត អ៊ំមានដែលជួបរឿងរ៉ាវ ដែលឃើញគេចាប់រំលោភមានទេ?

ថា ៖ ការចាប់រំលោភគ្មាន មានកាលនៅជួរព្រៃតាម៉ៅ ពោធិ៍វិតមានកូនទាហានខ្លះអាចប៉ះពាល់ខាងសីលធម៌ខ្លះដែរ ជាមួយ វាមិនអត់ទេ វាមាន ទាល់តិចតួច ។

សេងគា ៖ ប៉ុន្តែអ៊ំអត់ដែលបានឃើញទេ?

ថា ៖ អត់ដែលបានឃើញ ។

សេងគា ៖ ដូចថាអ៊ំប្រធានដែរ ដែលឃើញគេយកមក ចាប់ឈ្លើយសឹកយកមកពាំងមុខដើម្បីប្រយុទ្ធជាមួយគេ អ៊ំដែលធ្លាប់ឃើញអ៊ីចឹង ឬក៏អ្នកផ្សេងទៀតគេធ្វើអ៊ីចឹង?

ថា ៖ ចាប់ឈ្លើកសឹកម៉េច?

សេងគា ៖ ដូចចាប់វៀតណាមមកអ៊ីចឹង ទាហានវៀតណាម យកមកដាក់មុខ?

ថា ៖ យកទៅបាញ់ទៀត?

សេងគា ៖ យកទៅដាក់មុខ ដើម្បីយកទៅប្រយុទ្ធជាមួយវៀតណាម?

ថា ៖ អត់ទេ ។

សេងគា ៖ អត់ដែលមានទេ?

ថា ៖ អត់មានទេ ។

សេងគា ៖ អត់ដែលមានអ្នកណាធ្វើអ៊ីចឹង?

ថា ៖ បាទ!

សេងគា ៖ កងទ័ពនឹង ឬក៏មានកងទ័ពផ្សេងធ្វើដែរ?

ថា ៖ ចឹក៏មានក៏មិនដឹង បើកន្លែងមុខសញ្ញាខ្ញុំ គ្មាន កងពលខ្ញុំអត់ បើខ្ញុំនៅគ្មានធ្វើអ៊ីចឹងទេ ។

សេងគា ៖ កាលនឹងមេបញ្ជាការរបស់អ៊ំអីនឹង១-២នាក់នឹង ធ្វើបាបអ៊ំទេឬក៏ម៉េចដែរ គាត់ជាមនុស្សម៉េចដែរ?

ថា ៖ វាមិនដែលធ្វើបាបអីផង ចុះបើមិនប្រើកូនចៅវាហើយ ។

សេងគា ៖ បន្ទាប់ពីអ៊ំមកពី៧៩បែកហើយ អ៊ំនាំប្តីប្រពន្ធរស់នៅរកស៊ីនៅនេះ?

ថា ៖ បាទ! រកស៊ីនឹងរហូត ។

សេងគា ៖ ហើយអ្នកដែលធ្លាប់ធ្វើកូនទាហានអ៊ំ មានរស់នៅជិតអ៊ំទេ ឬអត់ទេ?

ថា ៖ មានវាស្លាប់អាមួយឈឺស្លាប់នៅនេះ ហើយអាមួយវាធ្លាប់នៅជាមួយ ប៉ុនវៀងផ្តេសផ្តាសអាសម និយាយផ្តេសផ្តាស ធ្លាប់ស្នាក់នៅកងជាមួយគ្នា ខ្ញុំមេកូនទាហាននឹង ។

សេងគា ៖ ពេលទាហានត្រូវរបួសត្រូវអីនឹង ថ្នាំពេទ្យអីព្យាបាលគ្រប់គ្រាន់ទេ?

ថា ៖ អឺ! តាម កាលនឹកឃើញជនទាន់លន់ នល់ វាមានការខ្វះខាតដែរ ជនទាន់ខ្លះអត់បញ្ជូនទៅ ។

សេដគា ៈ ដល់ពេលសម័យខ្មែរក្រហមអត់ខ្វះទេ?

ថា ៈ ជំនាន់ខ្មែរក្រហមវារៀងខ្វះខាតល្មមដល់ ថ្នាំយកពីចិនមក កាលនឹងមិនមែននេះ បានន័យថានយោបាយគេធ្វើ មានជំនួយមកពីចិន ឬបច្ចេកទេសវានៅមានទិញពីព្រៃនគរមក ចុះលុយហើយនឹងមាស គេមិនបន្ទិលយកអានឹងមកចិញ្ចឹមទ័ព មកមើលទ័ព មកមើលប្រជារាស្ត្រខ្លះៗ ហើយអីចឹងថ្នាំសន្លូវជួនវារៀងគួរសម ជួនវាអត់តិច ល្មមដល់ ល្មមរកបានហើយដល់ជំនាន់នេះ អានឹងៗ

សេដគា ៈ ចុះបើត្រូវគ្រាប់អីមានពេទ្យមានអីច្រើនមកព្យាបាលទេ?

ថា ៈ មក ពេទ្យៗវរសេនាតូច វរសេនាធំ កងពល ហើយដល់ហួសកងពល បញ្ជូនមកពេទ្យភូមិភាគ ពេទ្យមជ្ឈិមៗ

សេដគា ៈ ការហូបចុកអីសាមញ្ញធម្មតា?

ថា ៈ សាមញ្ញ កាលនេះខ្វះខាតតិចដែរ អាពេល៧៦ ៧០អី ដែលវាមានហូបសាច់ត្រីខ្លះអីទៅ

សេដគា ៈ ទាល់ដល់ឆ្នាំ៨០អីបានអ៊ំមានកូនម្នាក់?

ថា ៈ បាទ!

សេដគា ៈ ចុះអ៊ំកាលនឹង អ៊ំនៅធ្វើទ័ព អ៊ំមានជួបហេតុការណ៍អីដែលជួបប្រទះដែលខ្ញុំមិនទាន់សួរអ៊ំនៅចាំទេ?

ថា ៈ ដូចគ្មានជួបហេតុការណ៍អីដែល ខុសពីការដែលធ្វើសង្គ្រាម ការបាញ់អីនឹង គ្មានៗ

សេដគា ៈ អ៊ំមានដឹងថា អ៊ំទៅធ្វើនៅទ័ពជួរមុខ អ៊ំមានដឹងពួកអ្នកដែលនៅខាងក្រោយអត់បាយអត់ទឹក មានដឹងដំណឹងទេ?

ថា ៈ ទេ! ដំណឹង បើតាមឮគ្រាន់ដំណឹងថាអត់ខ្លះមានខ្លះ ហើយពិសេសមិនបានមកៗ

សេដគា ៈ អ៊ំមានគិតថាអត់ដល់ថ្នាក់នឹងដែរ ឬអត់ទេ?

ថា ៈ អត់ៗដឹងដល់ថ្នាក់នឹងទេ អត់ដឹងឮថាវាលងម៉ាឃុំសម្លាប់មនុស្ស...ទល់៧៩ចុះមកវ៉ាក់អើដឹងនឹងគេៗ

សេដគា ៈ ដឹងមានអារម្មណ៍ម៉េចដែរ?

ថា ៈ មានអារម្មណ៍ៗខឹង ខំតស៊ូចង់ស្លាប់ៗ

សេដគា ៈ ស្មានខាងក្រោយនឹងមានហូបចុកគ្រប់គ្រាន់ដែរ?

ថា ៈ អឺ! ស្មានធ្វើទៅមិនមានការកាប់សម្លាប់អីចឹងៗ

សេដគា ៈ ទាល់តែធ្វើមកបម្រើបក្សអស់ពីចិត្តហូបចុក ដល់មកក្រោយវិញឃើញអីចឹង អ៊ំនឹកឃើញ

ស្តាយក្រោយអត់?

ថា ៖ និយាយមិនស្តាយ តស៊ូចង់ស្លាប់បើស្លាប់ៗហើយ ដល់ធ្វើខុសដើម្បីបម្រើជាតិបម្រើប្រជាជន ដល់មកធ្វើខុសអីចឹង ក្តៅចិត្តចង់ស្លាប់ ។

សេងគា ៖ អ៊ំអត់ដឹងពីការសម្លាប់ក្រោយទេ?

ថា ៖ ដល់ថ្នាក់នឹងមិនអាចនៅដល់អីចឹង ។

សេងគា ៖ ចុះអ៊ំកាលនឹងមានបងប្អូនអីត្រូវគេសម្លាប់អីទេ បងប្អូនដែលនៅក្រោយៗអត់បានទៅជាមួយអីចឹង?

ថា ៖ មានគេសម្លាប់ ។

សេងគា ៖ ឪពុកម្តាយរស់ដល់សព្វថ្ងៃទើបនឹងស្លាប់ទេ ឬក៏ម៉េច?

ថា ៖ អឺ! ស្លាប់ប៉ុន្មានឆ្នាំហើយ យូរៗមិនមែនចាស់ទេ ។

សេងគា ៖ កាលសម័យប៉ុលពតអត់អីទេ?

ថា ៖ ហ្នឹង ។

សេងគា ៖ ចុះបងប្អូនអី កាលនឹងអ៊ំមានបងប្អូនប៉ុន្មាននាក់?

ថា ៖ បងប្អូនខ្ញុំមានមើល៤-៥ ស្រីៗ៤ ។

សេងគា ៖ ស្រី៤ ប្រុស១?

ថា ៖ ស្រី៣ ប្រុស៣ ។

សេងគា ៖ ស្រី៣ ប្រុស១?

ថា ៖ ខ្ញុំមិនបាននៅផ្ទះទើបមិនចាំប្រវត្តិបងប្អូន ។

សេងគា ៖ ប៉ុន្តែបងប្អូនអត់មានអីទាំងអស់?

ថា ៖ ចុះកាលពីតូចខ្ញុំទៅរៀន មិននៅផ្ទះ បន្ទាប់មកខ្ញុំចូលធ្វើ ដល់ហើយចុះមកខ្ញុំនេះ ។

សេងគា ៖ ប៉ុន្តែបងប្អូនអត់អីទាំងអស់?

ថា ៖ បងប្អូនស្លាប់តែបងថ្ងៃសក្តិ៣ប៉ូលីស ។

សេងគា ៖ ស្លាប់បងថ្ងៃសក្តិ៣ប៉ូលីសនឹង?

ថា ៖ បាទ!

សេងគា ៖ ក្រៅពីនឹងអត់អីទេ?

ថា ៖ បាទ! ហើយបើជីដូនមួយអីមាន មិនដឹងអ្នកណាខ្លះស្លាប់ច្រើន ខ្ញុំមិនបានតាមដានប្រវត្តិនឹង ។

សេងគា ៖ ចុះអ៊ំខាងខ្ញុំមកសួរប្រវត្តិរឿងអ៊ំៗភ័យ?

ថា ៖ ខ្ញុំភ័យអីខ្ញុំ ព្រោះខ្ញុំរស់នៅកន្លងមកអីចឹងហើយ មិនត្រឹមតែប្អូនឯងមកសួរណោ តាំងពីមុនមកគេដឹងហើយ ខ្ញុំគ្មានលាក់ណាប្រវត្តិរូបៗការពិតប្រវត្តិរូបនេះខ្ញុំនិយាយនេះ ខ្ញុំគ្មានលាក់ អត់លាក់ទេ ។

សេងគា ៖ គេហៅទៅនោះ តែខ្ញុំមកដល់ផ្ទះ?

ថា ៖ នេះការស្រាវជ្រាវជាក់ស្តែង មកដល់នឹង មិនអាចហៅទៅ ។

វ៉ាស៊ី ៖ គេហៅទៅខេត្តពីអង្គាល់?

ថា ៖ ហៅទៅខេត្តពាក់ព័ន្ធគេចោទប្រកាន់ទេ មិនមែនសុខៗហៅទៅទេ ។

សេងគា ៖ គេចោទប្រកាន់ម៉េចទៅរឿងអីទៅ?

ថា ៖ គេចោទប្រកាន់ថាខ្ញុំសេរីការ ។

សេងគា ៖ សេរីការមានន័យថាម៉េច?

ថា ៖ សេរីការ ខាងដែលកាលនឹងសេរីការ ខាងសីនសាននឹង ពួកអានឹងគេចោទអីចឹង ព្រោះកាលមុនខ្ញុំធ្វើខ្មែរក្រហម ហើយដល់អីចឹងមានក្បាក់ងារសំងាត់ខាងរដ្ឋាភិបាលនេះ ថាខ្ញុំចូលសេរីការ គេទៅរាយការណ៍កុហក ដល់ការពិតវាអត់ៗគេឲ្យមកវិញមក ។

សេងគា ៖ បន្ទាប់អីចឹងទៅ គេហៅទៅសួរនៅខេត្ត?

ថា ៖ ហៅសួរខេត្ត ។

សេងគា ៖ អ្នកណាមកហៅ?

ថា ៖ មានអីបញ្ជាពីខេត្តមក ។

សេងគា ៖ ហើយការនឹងគេសួរអីខ្លះ?

ថា ៖ គេសួរដូចគ្នា ប្រវត្តិគេដឹង គេនៅសួរយើងឆ្លើយត្រង់អត់ប្រវត្តិដើមអីចឹងណា ហើយសួរ

សេងគា ៖ ដល់អ៊ំឆ្លើយត្រង់អីចឹងគេអត់ថាអី?

ថា ៖ ដូចខ្ញុំថា និយាយតាមយើងធ្លាប់យើងនិយាយប្រាប់គេតាំងពីមុនគ្មានរឿង ចុះកាលខ្ញុំនៅព្រៃសណ្តែក គេមិនសរសេរប្រវត្តិហើយ អានៅ៧ខែនឹង ប្រវត្តិគេសួទ្រាំងត្រង់នៅខេត្តហើយ នៅមជ្ឈឹមហើយៗ ។ ហើយដល់អីចឹងគេសួរយើងបញ្ហានេះ "ហេតុអីបានគេចាប់ខ្លួន?"ដល់គេសួរប្រវត្តិហើយ មូលហេតុដែលចាប់ខ្លួន "ឥឡូវខ្ញុំថាមិនដឹងទេ" ថា"ខ្ញុំមិនដឹង ការពិតមិនដឹងមែន ឥឡូវបងរកយុត្តិធម៌ឲ្យខ្ញុំអ្នកណាអ្នកមកប្តឹងថាខ្ញុំមកនៅជាមួយ

សេរីការ ឬខ្ញុំធ្វើនយោបាយ ធ្វើចលនាអី តាមបណ្ដាញផ្សេងៗ ឲ្យបងឯងរកយុត្តិធម៌ឲ្យ អីចឹងហៅវាមកជួប បើខ្ញុំធ្វើមេ ខ្ញុំមិនអាចាំវាអស់ទេ មិនដឹងអាណាខ្លះទេ» ។

សេងគា ៖ ហើយយ៉ាងម៉េចទៅ?

ថា ៖ ដល់អីចឹង គាត់បញ្ជាក់ឡើងវិញ កាលនឹងតាឡេង ហ៊ីរ ប្រធាននគរបាលខេត្ត អត់មាន ជួបមកសួរទេ ។

សេងគា ៖ តាឡេង ហ៊ីរមកសួរម៉ង?

ថា ៖ បាទ! មកសួរ ថាឥឡូវនិយាយឲ្យត្រង់នឹងគ្នា កុំពិបាកលេបដុំគ្រួស ដុំថ្មៗ ពិតទេ បងឯង រកយុត្តិធម៌ខ្ញុំព្រោះខ្ញុំមកសុខចិត្តលះបង់ ទ័ពរាប់ពាន់ដែលខ្ញុំលះបង់មកធ្វើរាស្ត្រ ធ្វើប្រជាជនរកស៊ី ឥឡូវខ្ញុំបង្កើតចលនាអីមួយ បើខ្ញុំតាមអ្នកណាមួយ ។ ឥឡូវអ្នកណា អ្នកថារកយុត្តិធម៌ឲ្យខ្ញុំ ។

សេងគា ៖ ដល់រកឲ្យមិនឃើញវែងវិញ ។

ថា ៖ ចឹមិនឃើញអាពួកភ្ញាក់ផ្អារៗនឹង ភ្ញាក់ផ្អារសំងាត់នឹង ។

សេងគា ៖ អ្នកណាគេ?

ថា ៖ កុំចេញឈ្មោះពេក ព្រោះយើងថាគេមិនពិត ព្រោះមូលហេតុដល់ហើយក៏គេមិនប្រាប់ ឈ្មោះ ក ប្ដឹងយើងដែរ ក្រែងយើងនិយាយខុស កុំថាឈ្មោះគេ ។

សេងគា ៖ កាលនឹងនៅឆ្នាំដែលអ៊ំមកសួរនឹង?

ថា ៖ ឆ្នាំប៉ុន្មាន ។

សេងគា ៖ ប្រហែល៨០ប៉ុន្មាន?

ថា ៖ ខ្ញុំវៃចាន់ពី១១ឆ្នាំ ហើយសងជាមួយដែល៣១នោះ ២០ឆ្នាំហើយ ។

សេងគា ៖ ចូល៨០ជាង?

ថា ៖ បាទ! ៨០ជាងហ្នឹង ហើយជាប់២១ឆ្នាំ ២លើ ។

សេងគា ៖ បាទ! ៨៥?

ថា ៖ យូរហើយតាំងពី ។

សេងគា ៖ ចុះគេមកសួរអ៊ំប៉ុន្មានដងហើយ អារឿងនឹង?

ថា ៖ ការមុនប្រវត្តិហេតុមុនដំបូង សួរឬសគល់មុនដំបូងនៅព្រៃសណ្ដែកនោះទេ ខ្ញុំចុះមកពីលើ បាន២-៣ថ្ងៃ គេហៅចូលនៅសាលាស្រុកព្រៃសណ្ដែក ។ អីចឹងបានគេសួរប្រវត្តិហេតុដូច ខ្ញុំជម្រាបមុន គេសួរនៅកងពលលេខប៉ុន្មានឈ្មោះអី នៅកងពលលេខប៉ុន្មាន ឋានៈអីៗខ្លះ

ប្រាប់ហើយអស់អីចឹងទៅ ហើយអានឹងក៏អីចឹងដូចគ្នា ។ ហើយបានគេសួរពាក់ព័ន្ធថា ឥឡូវ ដែលថាធ្វើនយោបាយចលនាជាមួយសេរីការ ។ ហើយដល់អីចឹង យើងឆ្លើយថា យើងអត់ ប្រាប់គាត់ថា"ខ្ញុំអត់ទេ" "ចុះម៉េចអត់ បើអត់ម៉េចគេនាំខ្លួនមក" ខ្ញុំថា"រឿង នាំខ្លួនមកហ្នឹងខ្ញុំមិនដឹងខ្លួន ហើយខ្ញុំសុំនិយាយជាមួយបងឯង ឲ្យជួយរកយុត្តិធម៌ ឲ្យខ្ញុំ ព្រោះខ្ញុំមិនដឹងអ្នកណាដឹងណែ ថាខ្ញុំមិនឲ្យពាក់ព័ន្ធណាមួយ ឲ្យទៅបម្រើចលនានយោបាយ នឹង ឬខ្ញុំធ្វើខាងនឹងមួយទៀត បាញ់ខ្ញុំចោលតែម្តង ប៉ុនសុំជួបជាមួយអាអ្នកថា អ្នកនាំ នឹង" គ្រាន់និយាយ ។

សេងគា ៖ គេឲ្យជួបទេ?

ថា ៖ អត់ទេដល់អីចឹង គាត់បញ្ជាក់អានឹងគេនយោបាយ គេនិយាយណែនាំយើងថាស្មោះត្រង់អី ចូលធ្វើការ ហើយបើមិនស្មោះត្រង់លេបដុំគ្រោះដុំថ្មអីចឹងទៅ អានឹងវាអីចឹង ។ ហើយ ដល់ជាប់ថាអីចឹង ដូចទៅដេកគិតទៀត ។ ដេកគិត២ថ្ងៃឡើងឃើញ អានេះ...អាអ្នករាយ ការណ៍នឹង ភ្នាក់ងារសំងាត់ សួរៗខ្ញុំមិនប្រាប់ឈ្មោះដែរ ពីព្រោះអានេះគ្រាន់កាលវិភាគ គាត់ប្រាប់ថា"ខ្លាំងឆ្លើយដាក់" ហើយដល់ឃើញ២ថ្ងៃអាម្នាក់នឹងទៅ គាត់ហៅទៅជួបម្តង ទៀត ហើយខ្ញុំ ទំលាក់មិនឲខ្ញុំឃើញ ប៉ុនថ្ងៃនឹងគាត់ចេះដើរចេញទៅ ខ្ញុំឃើញវាចូលអា នឹង អាខ្ញុំនិយាយឈ្មោះនឹង ។ ហើយដល់អីចឹងគាត់ថា ឥឡូវការងារនេះនឹង ខ្លាំងឆ្លើយ ដាក់ ប៉ុនឥឡូវគាត់ប្រជុំនៅមជ្ឈឹម ហើយរាយការណ៍ទៅមជ្ឈឹម...ដល់ដកពាក្យវិញ អីចឹង ទ្រាំងទៅ ចាំមកពីសន្តិបាទគិតទៅម៉ាខែមួយថ្ងៃ ។

សេងគា ៖ នៅនឹងម៉ាខែម៉ាថ្ងៃ?

ថា ៖ គាត់មកឲ្យមកវិញមក ឲ្យធ្វើ ។

សេងគា ៖ មកវិញ មានមករកអីទៀតទេ?

ថា ៖ អត់ទេ ។

សេងគា ៖ ឈប់មករកទៀតទៅ ទើបខាងខ្ញុំមកសម្ភាសន៍?

ថា ៖ អឺ! មិនដែលមក គ្មានពាក់ព័ន្ធ ហៅទៅធ្វើការវិញ តែមិនទៅ ។

សេងគា ៖ ចុះអីដែលពុគុលាការគាត់ទោសមេដឹកនាំខ្មែរក្រហមធំៗ ?

ថា ៖ អឺ! តាមវ៉ាដ្យូ ពុខ្លះ អត់ខ្លះ ស្តាប់ខ្លះ អត់ខ្លះ ។

សេងគា ៖ កាលនឹងអីដឹងថានរណាខ្លះធំៗនឹង ដែលគាត់ទោសនឹង?

ថា ៖ អឺ! គិតនិយាយមិនចាំ ប៉ុន្មានឆ្នាំនិយាយប៉ុន្មានឆ្នាំហើយ ។

សេដ្ឋកា ៖	នរណាគេខ្លះ?

ថា ៖	ដូចថាឌុច, នួន ជា, ខៀវ សំផន, អៀង សារី, ហើយប្រពន្ធឈ្មោះអី អៀង ធារិទ្ធ ។

សេដ្ឋកា ៖	អ៊ំនៅចាំទាំងអស់?

ថា ៖	និយាយមិនចាំ ផ្សាយក្នុងនឹង ។

សេដ្ឋកា ៖	ឌុចនឹង គេចេញសាលក្រមសម្រេចនៅថ្ងៃទី២៦នឹង ថាគាត់នឹងត្រូវមានទោសប៉ុន្មាន ឬក៏ ត្រូវដោះលែងម៉េច ២៦ខែនឹង បើអ៊ំមានទូរទស្សន៍អីចឹងអាចបើកមើលដឹងហើយ ។

ថា ៖	កាត់ប៉ុន្មានឆ្នាំៗ ។

សេដ្ឋកា ៖	ប្រហែលអត់លែង ព្រោះការគាត់ទទួលខុសត្រូវធំៗប្រហែលជាអត់លែងទេ អានឹងសម្រេចលើតុលាការ ខាងខ្ញុំក៏អត់ដឹងដែរ រាល់ថ្ងៃនឹងបានយើងមើលទាំងអស់គ្នា ព្រោះខាងខ្ញុំមិនមែនជាតុលាការទេ ជាអង្គការ គ្រាន់ស្រាវជ្រាវឯកសាររឿងពិតដូចអ៊ំអីចឹងមានរឿងពិត ដូចពូមានរឿងពិតអី ដើម្បីចងក្រងជាប្រវត្តិសាស្ត្រទុកស្រាវជ្រាវក្មេង ស្រាវជ្រាវជាឯកសារផ្សេងៗទៀត ។

ថា ៖	គិតទៅជារឿងពិតរបស់ខ្ញុំ មានប្រវត្តិតស៊ូប៉ុននឹង តស៊ូគិតទៅវាខុសត្រូវស្រេចការវិភាគប៉ុនរឿងការបាញ់បោះ ។

សេដ្ឋកា ៖	ចុះអ៊ំតស៊ូអីចឹង អ៊ំមានត្រូវគ្រាប់ត្រូវអីទេ?

ថា ៖	ត្រូវ ។

សេដ្ឋកា ៖	ត្រូវកន្លែងណាខ្លះ?

ថា ៖	ត្រូវមាត់នឹងហើយ ខ្លះនឹងៗជើងអីចឹង ។

សេដ្ឋកា ៖	ត្រូវញឹកញាប់ដែរ ប៉ុន្មែអត់អី?

ថា ៖	៤-៥ដងដែរនឹង ។

សេដ្ឋកា ៖	ខ្ញុំដូចអស់អីសួរអ៊ំហើយ ចុងក្រោយអ៊ំមានអីចង់សួរខ្ញុំវិញ?

ថា ៖	ទេ! ឥឡូវខ្ញុំមិនដឹងសួរអី ហើយការខ្ញុំជម្រាបជូន គិតទៅដូចខ្ញុំនិយាយដូចខ្ញុំថាវាគ្រាន់ថយមុខថយក្រោយ ប៉ុនការពិតកន្លងមកវាគ្មានហៅថាការបាញ់បោះ ការសម្លាប់ស្រស់ដោយចាប់យកទៅបាញ់ទៅសម្លាប់អីវាគ្មាន មានតែបាញ់បោះជាមួយយោធាដូចគ្នានឹង ។

សេដ្ឋកា ៖	អ៊ំមានចង់និយាយអីរឿងផ្សេងទៀតទេ?

ថា ៖	រឿងផ្សេងៗខ្ញុំក៏មិនដឹងនិយាយថាម៉េច ។

សេងគា ៖ បាទ! បើអ៊ំអត់មានអីទេ ខ្ញុំក៏នេះ បើអ៊ំឆ្ងល់អីចង់សួរខ្ញុំវិញ អាចសួរខ្ញុំបាន កុំឲ្យសង្ស័យ មានមន្ទិលសង្ស័យជាមួយគ្នាអីចឹង ។

ថា ៖ ចុះឥឡូវសង្ស័យអី បើយើងនិយាយតាមប្រវត្តិដែលយើងធ្លាប់ធ្វើតាមការដឹកនាំ មេដឹកនាំកន្លងមក តាមរបបកន្លងមក ហើយដល់យើងគាត់ចង់និយាយប្រវត្តិអត់ដឹងប្រវត្តិចង់និយាយការពិត ការដឹងអ្នកណាជាអ្នកសម្លាប់ ឬធ្វើបាបរាស្ត្រធ្វើបាបប្រជាជនសម្លាប់ប្រជាជនដោយរបៀបណាឲ្យវាដឹង ឥឡូវយើងវាមិនដែល យើងមានតែប្រឆាំងជាមួយអ្នកមានអាវុធដូចគ្នា មានតែប៉ុននឹង ។

សេងគា ៖ អ៊ំមានស្គាល់អ្នកណាគេ ដូចប្រធានធ្លាប់ធ្វើពេទ្យធ្វើអីមុនមកមានស្គាល់ទេ នៅភូមិនឹង ខ្ញុំចង់សួរគាត់ដែរ?

ថា ៖ ពេទ្យ! គ្មានទេ ។

សេងគា ៖ ធ្វើពេទ្យកាលធ្វើពេទ្យនៅសម័យខ្មែរក្រហមនឹង គាត់ធ្វើពេទ្យធ្វើអី?

ថា ៖ គ្មានទេ ។

សេងគា ៖ អ៊ំនៅនេះ ភូមិនេះមានគុកមានអីប៉ុន្មានកន្លែង?

ថា ៖ អឺ! មិនដឹងដែលសួរគេ អានេះមានដែលស្គាល់ប៉ុន្មានកន្លែង ។

សេងគា ៖ មានដឹងគុកនៅនេះមានទេ នៅភូមិនឹង?

មិនស្គាល់ ៖ គុកនៅនឹង គ្មានដឹងទេ គុកនៅនឹង ខ្ញុំមិនដែលស្គាល់ ។ តាមបញ្ហា កាលអាពតខ្ញុំគេឲ្យទៅនៅសោម ។

សេងគា ៖ អត់ដឹងទេ?

ថា ៖ អត់ដឹង បើគ្មាន បើតាមប្រវត្តិចាស់ៗគ្មានពូនិយាយឲ្យខ្ញុំ ។

វ៉ាស៊ី ៖ ខ្ញុំអត់ទាន់ច្បាស់រឿងដែលជម្លៀសឲ្យទៅនៅសោម?

មិនស្គាល់ ៖ បាទ!

វ៉ាស៊ី ៖ នៅឆ្នាំណាដែលគេជម្លៀសឲ្យទៅ?

មិនស្គាល់ ៖ ទើបនឹងទៅ ។

វ៉ាស៊ី ៖ ចុះពី៧៥មកនៅណា?

មិនស្គាល់ ៖ ពី៧៥មកនៅនឹង ។

វ៉ាស៊ី ៖ ៧៧បានទៅនៅសោម?

មិនស្គាល់ ៖ បាទ!

រ៉ាស៊ី ៖ មូលហេតុអីទៅបានគេឲ្យទៅ?

មិនស្គាល់ ៖ ហោ៎! សោមអត់មានប្រជាជន គេយកពីនឹងទៅ ។

រ៉ាស៊ី ៖ ចុះនេះបានអ្នកណាមកនៅ?

មិនស្គាល់ ៖ ហ្នឹងអត់មាន ។

សេងគា ៖ អីចឹង ខ្ញុំអត់មានអីសួរអ៊ំទៀតទេ អរគុណអ៊ំច្រើន ដែលអ៊ំចំណាយពេលវេលាខំរៀបរាប់ រឿងរ៉ាវប្រាប់ខ្ញុំ ។ បាទ!អរគុណអ៊ំជម្រាបលា ។

«ចប់»